ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍ត្រួតពិនិត្យ ប្រចាំឆ្នាំ ២០២៤

អគ្គនាយកដ្ឋានត្រួតពិនិត្យ

# អារម្ភកថា



សេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២៤ នៅបន្តប្រឈមនឹងបញ្ហាមួយចំនួន ដូចជា ការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ជម្លោះនៅមជ្ឈិមបូព៌ា កម្រិតអត្រាការប្រាក់ខ្ពស់នៅលើទីផ្សារអន្តរជាតិ ការថមថយកំណើនសេដ្ឋកិច្ចចិន និងការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច ជាដើម។ មូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថា នៅឆ្នាំ២០២៤ សេដ្ឋកិច្ចពិភពលោកបន្តមានកំណើនក្នុងអត្រា ៣,២% ដោយក្នុងនោះ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍មានកំណើន ១,៧% សេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍មានកំណើន ៤,២% និងសេដ្ឋកិច្ចប្រទេសអាស៊ាន-៥[១] មានកំណើន ៤,៦%។ ចំណែកសេដ្ឋកិច្ចកម្ពុជា មានកំណើន ៦,០% នៅឆ្នាំ២០២៤ ប៉ុន្តែសម្រាប់ឆ្នាំ២០២៥ ទាំងមូល កំណើននេះត្រូវបានរំពឹងថាអាចនឹងមានកម្រិតទាបជាងឆ្នាំមុន ដោយសារផលប៉ះពាល់មកលើការនាំចេញរបស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិក អាចនឹងកើតមាននៅឆមាសទី២ ជាពិសេស ប្រសិនបើគោលនយោបាយពន្ធបដិការរបស់សហរដ្ឋអាមេរិកមិនមានភាពធូរស្រាលនោះទេ។ ការរក្សាបាននូវសន្តិភាព និងស្ថិរភាពនយោបាយ គឺជាធាតុដ៏សំខាន់ និងមិនអាចកាត់ផ្តាច់ចេញពីការគាំទ្រកំណើននេះ ហើយក៏ជាសមិទ្ធផលដ៏ធំធេងរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានខិតខំអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ រយៈពេលជាងមួយឆ្នាំកន្លងមក។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជា បន្តចូលរួមយ៉ាងសកម្មក្នុងការគាំទ្រគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ដូចជា "យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨" របស់រាជរដ្ឋាភិបាលដែលមានគោលដៅគាំពារ និងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់អ្នកប្រកបអាជីវកម្ម និងធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក៏ដូចជាអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីក្លាយទៅជាកម្លាំងចលករដ៏សំខាន់រួមចំណែកជាអតិបរមាក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងភាពរឹងមាំ។

ក្នុងបរិការណ៍ដែលស្ថានភាពសេដ្ឋកិច្ចសកលនិងតំបន់ស្ថិតក្នុងភាពមិនប្រាកដប្រជា ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចាំបាច់ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នខ្ពស់ ក្នុងគោលដៅពង្រឹងភាពធន់ទាំងក្នុងកម្រិតគ្រឹះស្ថាននីមួយៗ និងកម្រិតប្រព័ន្ធទាំងមូល។ ក្នុងន័យនេះ ការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ការធ្វើស្ត្រេសតេស្ត និងការចុះត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានអនុវត្តប្រកបដោយភាពហ្មត់ចត់ ដើម្បីវាយតម្លៃហានិភ័យ និងដាក់ចេញនូវវិធានការបុរេសកម្មនានា។ ធនាគារជាតិនៃកម្ពុជា បានបន្តដាក់ចេញនូវវិធានការអនុគ្រោះផ្នែកបទប្បញ្ញត្តិមួយចំនួន ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច រួមទាំងជួយសម្រាលបន្ទុកចំណាយប្រចាំគ្រារបស់អតិថិជនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមរយៈសេចក្តីជូនដំណឹង ស្តីពីការអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញចំពោះវិស័យទេសចរណ៍ នៅខេត្តសៀមរាប និងការដាក់ចេញបន្ថែមនូវសារាចរណែនាំក្នុងឆ្នាំ២០២៤ ស្តីពីការរៀបចំឥណទានឡើងវិញ ដែលអនុញ្ញាត

[១] រួមមាន៖ ប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ

ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញជូនអតិថិជន ដើម្បីជួយសម្រាលបន្ទុកចំណាយប្រចាំគ្រារបស់អតិថិជនក្នុងការបំពេញកាតព្វកិច្ចសងត្រឡប់ និងជំរុញកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើនលំហូរសាច់ប្រាក់។ ធនាគារជាតិនៃកម្ពុជា ក៏បាននិងកំពុងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិមួយចំនួនទៀត ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍនៃប្រព័ន្ធធនាគារកម្ពុជា និងស្របតាមស្តង់ដាត្រួតពិនិត្យអន្តរជាតិ ជាពិសេសស្តង់ដាបាសែល។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បន្តលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន តាមរយៈការសហការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ ក្នុងការអនុវត្តផែនការសកម្មភាពនានា ស្របតាមយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។ ធនាគារជាតិនៃកម្ពុជា យកចិត្តទុកដាក់ខ្ពស់ចំពោះការអភិវឌ្ឍហិរញ្ញវត្ថុបៃតង ការប្រែប្រួលអាកាសធាតុ និងការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ដើម្បីចូលរួមគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព។

ធនាគារជាតិនៃកម្ពុជា បន្តធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាចូលរួមគាំទ្រដល់គោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលរបស់រាជរដ្ឋាភិបាល។ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ត្រូវបានពង្រីកវិសាលភាពជាបន្តបន្ទាប់តាមរយៈកិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្សេងៗទៀតក្នុងតំបន់ និងដៃគូសហការនានា ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ ឱ្យមានភាពងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាព។

ធនាគារជាតិនៃកម្ពុជា បន្តការយកចិត្តទុកដាក់អភិវឌ្ឍធនធានមនុស្ស ទាំងសមត្ថភាពជំនាញ និងឯកទេសកម្ម តាមរយៈការបណ្តុះបណ្តាលនានាដែលត្រូវបានរៀបចំឡើងជាប់ជាប្រចាំ ទាំងក្នុង និងក្រៅប្រទេស និងការសិក្សាតាមរយៈប្រព័ន្ធអនឡាញ ក៏ដូចជាការចែករំលែកចំណេះដឹងផ្ទៃក្នុងផងដែរ។ ជាក់ស្តែង មន្ត្រីត្រួតពិនិត្យត្រូវបានអនុញ្ញាតឱ្យចូលរួមកម្មវិធីបណ្តុះបណ្តាលជាច្រើនដើម្បីទទួលបានទាំងទ្រឹស្តីនិងការអនុវត្តជាក់ស្តែង សំដៅពង្រឹងគុណវុឌ្ឍិរបស់មន្ត្រីត្រួតពិនិត្យ និងជំរុញការអនុវត្តការងារប្រចាំថ្ងៃឱ្យកាន់តែមានប្រសិទ្ធភាព និងនិរន្តរភាព។

ខ្ញុំសង្ឃឹមថា របាយការណ៍នេះផ្តល់នូវប្រភពព័ត៌មានយ៉ាងសំខាន់សម្រាប់បង្កើនការយល់ដឹងបន្ថែមអំពីប្រព័ន្ធធនាគារនៅកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៥

**ជា សិរី**

**ទេសាភិបាល**

**ធនាគារជាតិ នៃ កម្ពុជា**

# មាតិកា


**អារម្ភកថា** ............ i

**អក្សរកាត់** ............ v

**បញ្ជីក្រាហ្វ និងតារាង** ............ vii

**១. ការអភិវឌ្ឍប្រព័ន្ធធនាគារ** ............ **១**

១.១. ទិដ្ឋភាពទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ............ ១

១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ ............ ១

១.២.១. ប្រតិបត្តិការនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ............ ៣

១.២.១.១. ប្រតិបត្តិការនៃធនាគារពាណិជ្ជ ............ ៣

១.២.១.២. ប្រតិបត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ............ ៦

១.២.២. ប្រតិបត្តិការនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ............ ៨

១.២.២.១. ប្រតិបត្តិការនៃធនាគារឯកទេស ............ ៨

១.២.២.២. ប្រតិបត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ............ ១០

១.២.២.៣. ប្រតិបត្តិការនៃគ្រឹះស្ថានភតិសន្យាហិញ្ញវត្ថុ ............ ១១

១.២.២.៤. ប្រតិបត្តិការនៃគ្រឹះស្ថានឥណទានជនបទ ............ ១២

១.២.៣. ប្រតិបត្តិការនៃគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ............ ១៣

១.២.៤. អាជីវកម្មប្តូរប្រាក់ ............ ១៣

១.៣. ប្រតិបត្តិការនៃទីផ្សារអន្តរធនាគារ ............ ១៤

**២. ការវិវឌ្ឍនៃក្របខ័ណ្ឌត្រួតពិនិត្យនិងបទប្បញ្ញត្តិ** ............ **១៤**

២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ ............ ១៤

២.២. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ............ ១៦

២.២.១. សកម្មភាពនៃការត្រួតពិនិត្យ ............ ១៦

២.២.២. ឥណទានរៀបចំឡើងវិញ ............ ១៦

២.៣. ហិរញ្ញវត្ថុប្រកបដោយចីរភាព ............ ១៧

២.៤. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ ............ ១៨

**៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់** ............ **១៩**

៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ............ ១៩

៣.១.១. បច្ចេកវិទ្យាហិរញ្ញវត្ថុ ............ ១៩

៣.១.២. ប្រព័ន្ធទូទាត់សងប្រាក់ ............ ១៩

៣.១.៣. ការអនុវត្តស្តង់ដាគណនេយ្យ ............ ២០

៣.១.៤. ការចែករំលែកព័ត៌មានឥណទាន ............ ២១

៣.២. ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ........ ២៣
៣.២.១. ការអប់រំផ្នែកហិរញ្ញវត្ថុ ........ ២៤
៣.២.១.១. សិក្ខាសាលាផ្សព្វផ្សាយអំពីវិស័យមីក្រូហិរញ្ញវត្ថុ ........ ២៤
៣.២.១.២. ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ........ ២៥
៣.២.១.៣. ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី ........ ២៥
៣.២.១.៤. យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយៈ តក់ៗពេញបំពង់" ........ ២៦
៣.២.១.៥. គម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍" ........ ២៦
៣.២.២. កិច្ចការពារអតិថិជន ........ ២៧
**៤. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការ ........ ២៧**
៤.១. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ ........ ២៧
៤.២. កិច្ចសហប្រតិបត្តិការជាតិ ........ ២៨
៤.២.១. អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ........ ២៨
៤.២.២. អគ្គស្នងការដ្ឋាននគរបាលជាតិ ........ ២៨
៤.២.៣. កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ ........ ២៩
៤.២.៤. សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ........ ២៩
៤.៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ ........ ២៩
៤.៣.១. គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ ........ ២៩
៤.៣.២. សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ ........ ៣០
៤.៣.៣. សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ........ ៣០
៤.៣.៤. សមាគមឥណទានកសិកម្មនិងជនបទ សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ........ ៣១
**បញ្ជីឧបសម្ព័ន្ធ ........ ៣២**

# អក្សរកាត់

| អក្សរកាត់ | ពាក្យពេញភាសាអង់គ្លេស | ពាក្យពេញភាសាខ្មែរ |
|---|---|---|
| ADA | Appui au Développement Autonome | អង្គការ Appui au Développement Autonome |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFI | Alliance for Financial Inclusion | សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ |
| AI | Artificial Intelligence | បញ្ញាសិប្បនិម្មិត |
| APRACA | Asia-Pacific Rural and Agricultural Credit Association | សមាគមឥណទានកសិកម្ម និងជនបទសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក |
| ATM | Automatic Teller Machine | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ |
| BAKC | Bar Association of the Kingdom of Cambodia | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| BAKONG | Bakong Payment System | ប្រព័ន្ធទូទាត់បាគង |
| BFIs | Banks and Financial Institutions | គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ |
| BIS | Bank for International Settlement | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ |
| BSRS | Bank Supervision Reporting System | ប្រព័ន្ធរបាយការណ៍ត្រួតពិនិត្យ |
| CIFRS | Cambodian International Financial Reporting Standard | ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា |
| CIFRS for SMEs | Cambodian International Financial Reporting Standard for SMEs | ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម |
| CSS | Cambodian Shared Switch | ប្រព័ន្ធខេមបូឌានស៊ែស្វីច |
| ECL | Expected Credit Loss | ការខាតបង់ឥណទានរំពឹងទុក |
| e-KYC | Electronic Know Your Customer | ការចុះឈ្មោះអតិថិជនជាអេឡិចត្រូនិក |
| ESG | Environment, Social and Governance | គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច |
| e-Wallet | Electronic Wallet | កាបូបអេឡិចត្រូនិក |
| FAST | Fast Payment System | ប្រព័ន្ធសេវាទូទាត់រហ័ស |

| | | |
|---|---|---|
| IFC | International Finance Corporation | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| FTC | Financial Transparency Corridor | ថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| IT Incidents | Information Technology Incidents | ឧបទ្ទវហេតុព័ត៌មានវិទ្យា |
| KHQR Code | KHQR Code standard | ស្តង់ដាខេអេចឃ្យូអរកូត |
| LPCO | Liquidity Providing Collateralized Operation | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា |
| MLF | Marginal Lending Facility | ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី |
| NCD | Negotiable Certificate of Deposit | មូលបត្រអាចជួញដូរបាន |
| NCS | National Clearing System | ប្រព័ន្ធផាត់ទាត់ជាតិ |
| NPL | Non-Performing Loan | ឥណទានមិនដំណើរការ |
| PISA | Programme for International Student Assessment | កម្មវិធីសម្រាប់ការវាយតម្លៃនិស្សិតអន្តរជាតិ |
| POS | Point of Sale Machine | ម៉ាស៊ីនទូទាត់បណ្ណឥណពន្ធ-ឥណទាន |
| RETAIL PAY | Retail Payment System | ប្រព័ន្ធរីថៃលផេ |
| ROA | Return on Asset | ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម |
| ROE | Return on Equity | ប្រាក់ចំណេញធៀបនឹងដើមទុន |
| SEACEN | The South East Asian Central Banks Research and Training Centre | មជ្ឈមណ្ឌល ស៊ាសិន |
| UNCDF | United Nations Capital Development Fund | មូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ |
| UNESCAP | United Nations Economic and Social Commission for Asia and the Pacific | គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ |
| WB | World Bank | ធនាគារពិភពលោក |

# បញ្ជីក្រាហ្វ និងតារាង

## ក្រាហ្វ

ក្រាហ្វ ១ ៖ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........................................ ២
ក្រាហ្វ ២ ៖ ឥណទាននិងប្រាក់បញ្ញើអតិថិជន នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ............ ២
ក្រាហ្វ ៣ ៖ ធនាគារពាណិជ្ជ - ឥណទានតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច ........................ ៤
ក្រាហ្វ ៤ ៖ ធនាគារពាណិជ្ជ - ឥណទាន និងប្រាក់បញ្ញើអតិថិជន .................................. ៤
ក្រាហ្វ ៥ ៖ ធនាគារពាណិជ្ជ - ចំនួនគណនីឥណទាន និងគណនីប្រាក់បញ្ញើអតិថិជន ...... ៤
ក្រាហ្វ ៦ ៖ ធនាគារពាណិជ្ជ - ចំនួនបណ្ណឥណទាន និងបណ្ណឥណពន្ធ ......................... ៥
ក្រាហ្វ ៧ ៖ ធនាគារពាណិជ្ជ - អត្រាការប្រាក់មធ្យមលើឥណទាន និងប្រាក់បញ្ញើ ........... ៥
ក្រាហ្វ ៨ ៖ ធនាគារពាណិជ្ជ - អនុបាតឥណទានមិនដំណើរការ ....................................... ៦
ក្រាហ្វ ៩ ៖ មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ទ្រព្យសកម្ម និងកំណើន ............................. ៦
ក្រាហ្វ ១០ ៖ មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ឥណទាននិងប្រាក់បញ្ញើអតិថិជន ............... ៦
ក្រាហ្វ ១១ ៖ មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ឥណទានតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច.... ៧
ក្រាហ្វ ១២ ៖ មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - អត្រាការប្រាក់មធ្យមលើឥណទាន និងប្រាក់បញ្ញើ ........................................................................................ ៧
ក្រាហ្វ ១៣ ៖ ធនាគារឯកទេស - ទ្រព្យសកម្ម និងកំណើន ................................................ ៨
ក្រាហ្វ ១៤ ៖ ធនាគារឯកទេស - ឥណទានអតិថិជន និងកំណើន ....................................... ៨
ក្រាហ្វ ១៥ ៖ ធនាគារឯកទេស - ឥណទានតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច......................... ៩
ក្រាហ្វ ១៦ ៖ ធនាគារឯកទេស - អត្រាការប្រាក់មធ្យមលើឥណទាន ................................. ៩
ក្រាហ្វ ១៧ ៖ ធនាគារឯកទេស - អនុបាតប្រាក់ចំណេញនិងឥណទានមិនដំណើរការ ......... ៩
ក្រាហ្វ ១៨ ៖ មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - ទ្រព្យសកម្ម និងកំណើន.................... ១០
ក្រាហ្វ ១៩ ៖ មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - កំណើនឥណទានអតិថិជន ................ ១០
ក្រាហ្វ ២០ ៖ មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - ឥណទានតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច . ១០
ក្រាហ្វ ២១ ៖ មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - អនុបាតប្រាក់ចំណេញនិងឥណទានមិនដំណើរការ ........................................................................ ១១
ក្រាហ្វ ២២ ៖ ភតិសន្យាហិរញ្ញវត្ថុ - ភតិសន្យាហិរញ្ញវត្ថុតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច...... ១២
ក្រាហ្វ ២៣ ៖ ភតិសន្យាហិរញ្ញវត្ថុ - អនុបាតប្រាក់ចំណេញនិងភតិសន្យាហិរញ្ញវត្ថុមិនដំណើរការ ........................................................................................ ១២

ក្រាហ្វ ២៤ ៖ អាជីវកម្មប្តូរប្រាក់ - ប្រភេទអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត ........................ ១៣
ក្រាហ្វ ២៥ ៖ អាជីវកម្មប្តូរប្រាក់ - ចំនួនលិខិតអនុញ្ញាតនៅតាមបណ្តាខេត្ត ...................... ១៤
ក្រាហ្វ ២៦ ៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - គ្រឹះស្ថានជាសមាជិក ............ ២១
ក្រាហ្វ ២៧ ៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - សំពៀតឥណទាន និងចំនួនគណនី ........................................................................................ ២១
ក្រាហ្វ ២៨ ៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - សំពៀតឥណទានបែងចែកតាមប្រភេទគ្រឹះស្ថានជាសមាជិក ........................................................ ២២
ក្រាហ្វ ២៩ ៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - ការប្រើប្រាស់របាយការណ៍ឥណទាន ........................................................................................ ២២

**តារាង**

តារាង ១ ៖ ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមប្រភេទភាគទុនិក ........... ១
តារាង ២ ៖ ការវិវឌ្ឍនៃធនាគារពាណិជ្ជ ................................................................ ៣
តារាង ៣ ៖ ការវិវឌ្ឍនៃភតិសន្យាហិរញ្ញវត្ថុ ........................................................ ១១

**ប្រអប់**

ប្រអប់ ៖ សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ទិវាសន្សំអាស៊ាន" ....................................... ២៤

# ទិន្នន័យទាំងអស់មិនទាន់ត្រូវបានធ្វើសវនកម្ម
# និងត្រូវបានរាយការណ៍ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ១. ការអភិវឌ្ឍប្រព័ន្ធធនាគារ

### ១.១. ទិដ្ឋភាពទូទៅនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ស្ថិតក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ធនាគារជាតិនៃកម្ពុជា បន្តអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជា តាមរយៈការលើកកម្ពស់គុណភាពនៃការត្រួតពិនិត្យ ព្រមទាំងការដាក់ចេញនូវបទប្បញ្ញត្តិ វិធានការចាំបាច់និងទាន់ពេលជាបន្តបន្ទាប់ ដើម្បីរក្សាបាននូវភាពធន់និងជំនឿទុកចិត្តរបស់សាធារណជនជាតិនិងអន្តរជាតិមកលើប្រព័ន្ធធនាគារនៅកម្ពុជា។ ប្រព័ន្ធធនាគារនៅកម្ពុជារួមមាន៖ ធនាគារពាណិជ្ជ ៥៩ ធនាគារឯកទេស ៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៥ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១៣ គ្រឹះស្ថានឥណទានជនបទ ១១៣ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ៣០ ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទាន ១ ការិយាល័យតំណាងធនាគារបរទេស ៥ និងអាជីវកម្មប្តូរប្រាក់ ៣.៣៣៤។

តារាង១៖ ចំណែកទីផ្សារនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុតាមប្រភេទភាគទុនិក (គិតជាភាគរយ)

| ចំណែកទីផ្សារ | ទ្រព្យសកម្ម | | ឥណទាន | | ប្រាក់បញ្ញើ | | ដើមទុន | |
|---|---|---|---|---|---|---|---|---|
| | ធ្នូ-២៣ | ធ្នូ-២៤ | ធ្នូ-២៣ | ធ្នូ-២៤ | ធ្នូ-២៣ | ធ្នូ-២៤ | ធ្នូ-២៣ | ធ្នូ-២៤ |
| **គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ** | | | | | | | | |
| ភាគទុនិកក្នុងស្រុក | ៣៣,១ | ៣០,៣ | ៣០,៩ | ២៧,១ | ៣៩,២ | ៣៤,៧ | ៣១,៦ | ២៧,៨ |
| ភាគទុនិកបរទេស | ៦៣,៤ | ៦៦,៥ | ៦៤,៧ | ៦៨,៥ | ៦០,៨ | ៦៥,៣ | ៥៩,៩ | ៦៤,០ |
| **គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ** | | | | | | | | |
| ភាគទុនិកក្នុងស្រុក | ០,៨ | ០,៩ | ១,០ | ១,២ | - | - | ៣,៣ | ៣,១ |
| ភាគទុនិកបរទេស | ២,៧ | ២,៣ | ៣,៤ | ៣,២ | - | - | ៥,២ | ៥,១ |
| **សរុបគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** | | | | | | | | |
| ភាគទុនិកក្នុងស្រុក | ៣៣,៩ | ៣១,២ | ៣១,៩ | ២៨,៣ | ៣៩,២ | ៣៤,៧ | ៣៤,៩ | ៣០,៩ |
| ភាគទុនិកបរទេស | ៦៦,១ | ៦៨,៨ | ៦៨,១ | ៧១,៧ | ៦០,៨ | ៦៥,៣ | ៦៥,១ | ៦៩,១ |
| **សរុប** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

### ១.២. ស្ថានភាព និងប្រតិបត្តិការហិរញ្ញវត្ថុ

ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន ៧,១% ដល់ ៣៧១,៧ ទ្រីលានរៀល (៩២,៣ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះឥណទានអតិថិជនមានកំណើន ២,៨% ដល់ ២៤២,៤ ទ្រីលានរៀល (៦០,២ ប៊ីលានដុល្លារអាមេរិក)។ ជាមួយគ្នានេះ ប្រាក់បញ្ញើអតិថិជនមានកំណើន ១៦,៦% ដល់ ២២៩,២ ទ្រីលានរៀល (៥៦,៩ ប៊ីលានដុល្លារអាមេរិក) និងដើមទុនមានកំណើន ៦,៦% ដល់ ៧០,៨ ទ្រីលានរៀល (១៧,៦ ប៊ីលានដុល្លារអាមេរិក)។

## ក្រាហ្វ ១៖ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ




## ក្រាហ្វ ២៖ ឥណទាន និងប្រាក់បញ្ញើអតិថិជន នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ







ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តកើនឡើង ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនឥណទាន និងប្រាក់បញ្ញើ ដោយក្នុងនោះ ចំនួនគណនីប្រាក់បញ្ញើអតិថិជន និងគណនីឥណទានអតិថិជនកើនឡើងដល់ ២៣,៧ លានគណនី និង ៤,០ លានគណនី រៀងគ្នា។ បណ្តាញប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានពង្រីកដល់ ២.៧៣៩ ទីតាំង ហើយចំនួនម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិបានកើនដល់ ៥.៨៩៦ និងម៉ាស៊ីនទូទាត់បណ្ណឥណពន្ធ-ឥណទានកើនដល់ ៤២.០៩៥ ដែលធ្វើឱ្យការប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែមានភាពងាយស្រួល និងទូលំទូលាយជាងមុន។

ស្របតាមនវានុវត្តន៍បច្ចេកវិទ្យា សេដ្ឋកិច្ច និងសង្គមឌីជីថល ធនាគារជាតិនៃកម្ពុជា បន្តអភិវឌ្ឍនិងធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអ្នកប្រើប្រាស់ក្នុងយុគសម័យឌីជីថល ដោយផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពសម្រួលការទូទាត់ពាណិជ្ជកម្ម និងសកម្មភាពសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។ នវានុវត្តន៍នៃឧបករណ៍ទូទាត់សងប្រាក់ និងការពង្រីកបណ្តាញទូទាត់ដែលមានសក្តានុពលបានធ្វើឱ្យការប្រើប្រាស់សេវាទូទាត់សងប្រាក់របស់សាធារណជន និងសហគ្រាសកាន់តែប្រសើរជាងមុន។

ជារួម ប្រព័ន្ធធនាគារនៅកម្ពុជា បន្តរួមចំណែកយ៉ាងសំខាន់ដល់ការគាំទ្រសកម្មភាពសេដ្ឋកិច្ចតាមរយៈការផ្តល់សេវាធនាគារដ៏សម្បូរបែប និងងាយស្រួល។

### ១.២.១. ប្រតិបត្តិការនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ រួមមាន៖ ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ជារួម ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន ៣៥៩,៧ ទ្រីលានរៀល (៨៩,៤ ប៊ីលានដុល្លារអាមេរិក) ដែលរួមចំណែក ៩៦,៨% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា។ ទន្ទឹមនេះ ប្រាក់បញ្ញើអតិថិជននៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បន្តមានកំណើនខ្ពស់ ១៦,៦% ដល់ ២២៩,២ ទ្រីលានរៀល (៥៦,៩ ប៊ីលានដុល្លារអាមេរិក) ខណៈដែលឥណទានអតិថិជនកើនឡើង ២,៨% ដល់ ២៣១,៨ ទ្រីលានរៀល (៥៧,៦ ប៊ីលានដុល្លារអាមេរិក)។

#### ១.២.១.១. ប្រតិបត្តិការនៃធនាគារពាណិជ្ជ

ទ្រព្យសកម្មសរុបរបស់ធនាគារពាណិជ្ជបន្តកើនឡើង ៨,១% ដល់ ៣៤២,១ ទ្រីលានរៀល (៨៤,៩ ប៊ីលានដុល្លារអាមេរិក)។ ប្រភពមូលនិធិរបស់ធនាគារពាណិជ្ជ មានដូចជា ប្រាក់បញ្ញើអតិថិជន ២១៩,៣ ទ្រីលានរៀល (៥៤,៥ ប៊ីលានដុល្លារអាមេរិក) មូលនិធិភាគទុនិក ៦៣,២ ទ្រីលានរៀល (១៥,៧ ប៊ីលានដុល្លារអាមេរិក) និងមូលនិធិកម្ចី ១៧,៦ ទ្រីលានរៀល (៤,៤ ប៊ីលានដុល្លារអាមេរិក)។

តារាង ២៖ ការវិវឌ្ឍនៃធនាគារពាណិជ្ជ (គិតជាភាគរយ)

| សូចនាករ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|
| កំណើនទ្រព្យសកម្ម | ១៩,៥ | ២០,៤ | ១១,៧ | ១៦,៤ | ៨,១ |
| កំណើនឥណទានអតិថិជន | ២៣,៦ | ២៦,៤ | ១៨,៣ | ១៤,៩ | ៣,១ |
| កំណើនប្រាក់បញ្ញើអតិថិជន | ១៧,២ | ១៧,៨ | ៨,៥ | ២១,៣ | ១៦,៩ |
| ទ្រព្យសកម្មធៀប ផ.ស.ស | ១៤១,០ | ១៦០,៤ | ១៦៤,៦ | ១៨០,៦ | ១៨៤,០ |
| ឥណទានអតិថិជនធៀប ផ.ស.ស | ៨៦,៣ | ១០៣,០ | ១១២,០ | ១២១,៣ | ១១៦,៩ |
| ប្រាក់បញ្ញើអតិថិជនធៀប ផ.ស.ស | ៨៥,១ | ៩៤,៨ | ៩៤,៥ | ១០៨,១ | ១១៧,៩ |

ឥណទានអតិថិជនបានកើនឡើង ៣,១% ដល់ ២១៧,៤ ទ្រីលានរៀល (៥៤,០ ប៊ីលានដុល្លារអាមេរិក)។ ឥណទានជាប្រភពទុនយ៉ាងសំខាន់ក្នុងការគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច និងបានបែងចែកទៅតាមប្រភេទជំនួញសំខាន់ៗ រួមមាន៖ សកម្មភាពផ្នែកអចលនទ្រព្យ ២៣,៨% អាជីវកម្មលក់រាយ ១៧,០% សំណង់ ១០,២% សកម្មភាពគ្រួសារជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់សេវាកម្ម ៩,៦% អាជីវកម្មលក់ដុំ ៩,១% កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ៩,០% កម្មន្តសាលកម្ម ៤,៥% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ៤,១% ការដឹកជញ្ជូននិងការស្តុកទុក ២,៩% និងឥណទានផ្សេងៗ ៩,៨%។

ក្រាហ្វ ៣៖ ធនាគារពាណិជ្ជ - ឥណទានតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច




ប្រាក់បញ្ញើអតិថិជននៅធនាគារពាណិជ្ជបានកើនឡើង ១៦,៩%។ ចំណែកទីផ្សារប្រាក់បញ្ញើ រួមមាន៖ ឯកត្តជន ៧១,៨% សហគ្រាសអាជីវកម្ម ១៧,៣% និងផ្សេងៗ ១០,៩%។ ចំនួនគណនីប្រាក់បញ្ញើនិងឥណទានបានបន្តកើនដល់ ២១,៧ លានគណនី និង ២,៣ លានគណនី រៀងគ្នា។ ការណ៍នេះក៏ឆ្លុះបញ្ចាំងពីការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើធនាគារពាណិជ្ជនៅកម្ពុជាផងដែរ។

ក្រាហ្វ ៤៖ ធនាគារពាណិជ្ជ - ឥណទាន និងប្រាក់បញ្ញើអតិថិជន




ក្រាហ្វ ៥៖ ធនាគារពាណិជ្ជ - ចំនួនគណនីឥណទាន និងគណនីប្រាក់បញ្ញើអតិថិជន



ស្របនឹងការរីកចម្រើននៃសេវាធនាគារ ការប្រើប្រាស់បណ្ណឥណទាននិងបណ្ណឥណពន្ធ ជំនួសសាច់ប្រាក់មានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយបណ្ណឥណទាននិងបណ្ណឥណពន្ធបានកើនដល់ ១៩៥.២៩៤ បណ្ណ និង ៥.០២៣.២៩៤ បណ្ណ រៀងគ្នា។ ធនាគារពាណិជ្ជបាននិងកំពុងបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនជាលំដាប់ ដោយម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិកើនឡើងដល់ ៥.៦៧៥ ព្រមទាំងបានពង្រីកបន្ថែមនូវសេវាហិរញ្ញវត្ថុឌីជីថលផងដែរ។ ទន្ទឹមនេះ ធនាគារពាណិជ្ជក៏បន្តផ្តល់សេវាយ៉ាងទូលំទូលាយតាមរយៈការពង្រីកបណ្តាញសាខាជាបន្តបន្ទាប់រហូតដល់ ១.៧៩៤ ទីតាំង។

ក្រាហ្វ ៦៖ ធនាគារពាណិជ្ជ - ចំនួនបណ្ណឥណទាន និងបណ្ណឥណពន្ធ




អត្រាការប្រាក់ជាមធ្យមលើប្រាក់បញ្ញើមានកម្រិត ៦,៣% ចំពោះប្រាក់រៀល និង ៥,៩% ចំពោះប្រាក់ដុល្លារអាមេរិក ប៉ុន្តែអត្រាការប្រាក់ជាមធ្យមលើឥណទានប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកស្ថិតក្នុងកម្រិត ១៣,០% និង ១១,០% រៀងគ្នា។

ក្រាហ្វ ៧៖ ធនាគារពាណិជ្ជ - អត្រាការប្រាក់មធ្យមលើឥណទាន និងប្រាក់បញ្ញើ




អនុបាតសាធនភាព និងអនុបាតគ្របខណ្ឌសន្ទនីយភាពមានកម្រិត ២២,៣% និង ១៩៩,៤% រៀងគ្នា។ លទ្ធភាពស្វែងរកប្រាក់ចំណេញត្រូវបានឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម ដែលមានកម្រិត ១,៥% និងអនុបាតប្រាក់ចំណេញធៀបនឹងដើមទុន ដែលមានកម្រិត ៨,៤%។

ទន្ទឹមនឹងអនុបាតឥណទានមិនដំណើរការមានកម្រិត ៧,២% ធនាគារពាណិជ្ជបានធ្វើចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនគ្រប់គ្រាន់ស្របតាមបទប្បញ្ញត្តិ ក៏ដូចជាបានចាត់ថ្នាក់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន និងគណនាការខាតបង់រំពឹងទុកស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ក្រាហ្វ ៨៖ ធនាគារពាណិជ្ជ - អនុបាតឥណទានមិនដំណើរការ




## ១.២.១.២. ប្រតិបត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានថយចុះ -៤,៣% មកត្រឹម ១៧,៦ ទ្រីលានរៀល (៤,៤ ប៊ីលានដុល្លារអាមេរិក) ខណៈដែលឥណទានអតិថិជនបានថយចុះ -១,៣% មកត្រឹម ១៤,៣ ទ្រីលានរៀល (៣,៥ ប៊ីលានដុល្លារអាមេរិក)។ ប្រាក់បញ្ញើអតិថិជនមានចំនួន ៩,៩ ទ្រីលានរៀល (២,៥ ប៊ីលានដុល្លារអាមេរិក) និងមូលនិធិភាគទុនិក ៣,៥ ទ្រីលានរៀល (០,៩ ប៊ីលានដុល្លារអាមេរិក)។

ក្រាហ្វ ៩៖ មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ទ្រព្យសកម្ម និងកំណើន




ក្រាហ្វ ១០៖ មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ឥណទាននិងប្រាក់បញ្ញើអតិថិជន




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បានបន្តចូលរួមចំណែកយ៉ាងសកម្មតាមរយៈការផ្តល់ឥណទានដល់ការពង្រីកមុខរបរអាជីវកម្ម និងការធ្វើកសិកម្ម សំដៅជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ ជាក់ស្តែង ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានបែងចែកទៅក្នុងវិស័យនៃសេដ្ឋកិច្ចរួមមាន៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២៧,០% អាជីវកម្មលក់រាយ ២១,៧% សកម្មភាពគ្រួសារជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់សេវាកម្ម ១៩,៤% សកម្មភាពផ្នែកអចលនទ្រព្យ ៦,១% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ៣,៩% សំណង់ ៣,៤% អាជីវកម្មលក់ដុំ ៣,៤% ការដឹកជញ្ជូននិងការស្តុកទុក ៣,២% កម្មន្តសាលកម្ម ១,៥% និងឥណទានផ្សេងៗ ១០,៤%។

ក្រាហ្វ ១១៖ មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - ឥណទានតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានចូលរួមចំណែកជំរុញបរិយាបន្នហិរញ្ញវត្ថុ តាមរយៈបណ្តាញប្រតិបត្តិការចំនួន ៨៣៦ ទីតាំង សម្រាប់ផ្តល់សេវាហិរញ្ញវត្ថុនៅទូទាំងប្រទេស ហើយចំនួនគណនីប្រាក់បញ្ញើបានបន្តកើនដល់ ២,១ លានគណនី និង គណនីឥណទាន ៩៨៣ ពាន់គណនី។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបាននិងកំពុងផ្តល់សេវាហិរញ្ញវត្ថុសម្បូរបែប ដូចជា សេវាឥណទាន ប្រាក់បញ្ញើ ផ្ទេរប្រាក់ ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ ជាដើម។

អត្រាការប្រាក់លើប្រាក់បញ្ញើនិងឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បានថយចុះ បើធៀបនឹងឆ្នាំ២០២៣ ដោយអត្រាការប្រាក់ជាមធ្យមលើប្រាក់បញ្ញើជារៀល មានកម្រិត ៧,៤% និងជាប្រាក់ដុល្លារអាមេរិក មានកម្រិត ៧,៥%។ ចំណែកអត្រាការប្រាក់ជាមធ្យមលើឥណទានជារៀលបានថយចុះពី ១៧,៦% (ឆ្នាំមុន) មកត្រឹម ១៧,៤% ខណៈដែលអត្រាការប្រាក់ជាមធ្យមលើឥណទានជាដុល្លារអាមេរិក បានថយចុះបន្តិចបន្តួចពី ១៦,៦% ក្នុងឆ្នាំ២០២៣ មកត្រឹម ១៦,៥% ក្នុងឆ្នាំ២០២៤។

ក្រាហ្វ ១២៖ មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ - អត្រាការប្រាក់មធ្យមលើឥណទាន និងប្រាក់បញ្ញើ




គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ រក្សាបាននូវអនុបាតប្រុងប្រយ័ត្នលើសកម្រិតបទប្បញ្ញត្តិដែលត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ក្នុងនោះរួមមាន៖ អនុបាតសាធនភាព និងអនុបាតក្របខ័ណ្ឌសន្ទនីយភាពមានកម្រិត ២៣,៨% និង ១៧៤,៩% រៀងគ្នា។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើនៅមានលទ្ធភាពស្វែងរកប្រាក់ចំណេញ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មក្នុងកម្រិត ១,៤% និងអនុបាតប្រាក់ចំណេញធៀបនឹងដើមទុនក្នុងកម្រិត ៧,១% ខណៈដែលអនុបាតឥណទានមិនដំណើរការមានកម្រិត ៦,២%។

ជារួម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបន្តរីកចម្រើន និងអនុលោមតាមបទប្បញ្ញត្តិប្រុងប្រយ័ត្នជាធរមាន។

### ១.២.២. ប្រតិបត្តិការនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ រួមមាន៖ ធនាគារឯកទេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ។ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើមានចំនួន ១១,៩ ទ្រីលានរៀល (៣,០ ប៊ីលានដុល្លារអាមេរិក) ដែលរួមចំណែក ៣,២% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា។ ទន្ទឹមនេះ ឥណទានអតិថិជនមានកំណើន ១,៨% ដល់ ១០,៦ ទ្រីលានរៀល (២,៦ ប៊ីលានដុល្លារអាមេរិក)។

#### ១.២.២.១. ប្រតិបត្តិការនៃធនាគារឯកទេស

ធនាគារឯកទេសជាគ្រឹះស្ថានដែលអនុវត្តនូវប្រតិបត្តិការណាមួយក្នុងចំណោមប្រតិបត្តិការទាំង ៣ នៃអាជីវកម្មធនាគារ ដែលរួមមាន៖ ១/-ផ្តល់ឥណទាន ២/-ទទួលប្រាក់បញ្ញើ និង ៣/-ដាក់ឱ្យប្រើប្រាស់នូវមធ្យោបាយទូទាត់ ឬ អនុវត្តតែផ្នែកមួយនៃសកម្មភាពទាំង ៣ នេះ ដោយបច្ចុប្បន្ន ធនាគារឯកទេសទាំងអស់ផ្តល់តែសេវាឥណទានប៉ុណ្ណោះ។ ទ្រព្យសកម្មរបស់ធនាគារឯកទេសមានកំណើន ១,៨% ដល់ ២,៧ ទ្រីលានរៀល (៦៦៧,៨ លានដុល្លារអាមេរិក) ដែលរួមចំណែក ០,៧% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា។ មូលនិធិភាគទុនិកបានកើនឡើង ៦,២% ដល់ ១,១ ទ្រីលានរៀល (២៧៦,៣ លានដុល្លារអាមេរិក)។

ក្រាហ្វ ១៣៖ ធនាគារឯកទេស - ទ្រព្យសកម្ម និងកំណើន




ក្រាហ្វ ១៤៖ ធនាគារឯកទេស - ឥណទានអតិថិជន និងកំណើន




ឥណទានអតិថិជនរបស់ធនាគារឯកទេសបានថយចុះ -០,៣% ដល់ ២,៣ ទ្រីលានរៀល (៥៦១,៦ លានដុល្លារអាមេរិក)។ ឥណទាននេះ បានរួមចំណែក ០,៩% នៃឥណទានសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា និងត្រូវបានផ្តល់ដល់វិស័យសំខាន់ៗក្នុងសកម្មភាពសេដ្ឋកិច្ច ដែលរួមមាន៖ សកម្មភាពគ្រួសារជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់សេវាកម្ម ៧៣,២% សកម្មភាពផ្នែកអចលនទ្រព្យ ១៤,២% អាជីវកម្មលក់រាយ ៣,២% អាជីវកម្មលក់ដុំ ២,៤% កម្មន្តសាលកម្ម ២,០% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ១,៨% សំណង់ ១,៣% កសិកម្ម រុក្ខាប្រមាញ់និងនេសាទ ១,០% ការដឹកជញ្ជូននិងការស្តុកទុក ០,៤% និងឥណទានផ្សេងៗ ០,៥%។

ក្រាហ្វ ១៥៖ ធនាគារឯកទេស - ឥណទានតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច




ទន្ទឹមនេះ អត្រាការប្រាក់ជាមធ្យមលើឥណទានជាប្រាក់រៀល បានកើនឡើងពី ១២,៩% (ឆ្នាំមុន) ដល់ ១៣,៤% ក្នុងឆ្នាំ២០២៤ ខណៈដែលអត្រាការប្រាក់ឥណទានជាដុល្លារអាមេរិក ប្រហាក់ប្រហែលនឹងឆ្នាំ២០២៣ ក្នុងកម្រិត ១២,៧%។

ក្រាហ្វ ១៦៖ ធនាគារឯកទេស - អត្រាការប្រាក់មធ្យមលើឥណទាន




អនុបាតឥណទានមិនដំណើរការរបស់ធនាគារឯកទេសបានកើនឡើងដល់ ១៣,៩% ដែលជាកត្តារួមចំណែកដល់ការធ្លាក់ចុះនៃអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងអនុបាតប្រាក់ចំណេញធៀបមូលនិធិភាគទុនិកដល់ -០,៧% និង -១,៧% រៀងគ្នា ។ ទោះជាយ៉ាងនេះក្តី ធនាគារឯកទេសនៅរក្សាបានអនុបាតសាធនភាពក្នុងកម្រិត ៤២,១% លើសកម្រិតកំណត់អប្បបរមា ដែលតម្រូវដោយបទប្បញ្ញត្តិប្រុងប្រយ័ត្ន។

ក្រាហ្វ ១៧៖ ធនាគារឯកទេស - អនុបាតប្រាក់ចំណេញនិងឥណទានមិនដំណើរការ



## ១.២.២.២. ប្រតិបត្តិការនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ

ទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ មានកំណើន ៤,៨% ដល់ ៧,៩ ទ្រីលានរៀល (១,៩ ប៊ីលានដុល្លារអាមេរិក) ខណៈដែលឥណទានអតិថិជនមានកំណើន ១០,៦% ដល់ ៧,១ ទ្រីលានរៀល (១,៧ ប៊ីលានដុល្លារអាមេរិក)។ បើប្រៀបធៀបនឹងប្រព័ន្ធធនាគារនៅកម្ពុជា ទ្រព្យសកម្ម និងឥណទានអតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើបានរួមចំណែក ២,១% និង ២,៩% រៀងគ្នា។

ក្រាហ្វ ១៨៖ មីក្រូហិរញ្ញវត្ថុ - ទ្រព្យសកម្ម និងកំណើន




ក្រាហ្វ ១៩៖ មីក្រូហិរញ្ញវត្ថុ - កំណើនឥណទានអតិថិជន




ឥណទានអតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ បន្តចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងត្រូវបានផ្តល់ដល់វិស័យសំខាន់ៗក្នុងសកម្មភាពសេដ្ឋកិច្ច រួមមាន៖ សកម្មភាពគ្រួសារជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់សេវាកម្ម ៤៤,៥% សកម្មភាពផ្នែកអចលនទ្រព្យ ៨,២% សំណង់ ៧,៥% អាជីវកម្មលក់រាយ ៥,៦% កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៥,៥% កម្មន្តសាលកម្ម ៤,៣% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ៣,២% ការដឹកជញ្ជូននិងការស្តុកទុក ២,៦% អាជីវកម្មលក់ដុំ ១,៧% និងឥណទានផ្សេងៗ ១៦,៩%។

ក្រាហ្វ ២០៖ មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - ឥណទានតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច




អនុបាតឥណទានមិនដំណើរការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើបានកើនឡើងដល់ ១៥,៥% ដែលជាកត្តារួមចំណែកដល់ការធ្លាក់ចុះនៃអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និងអនុបាតប្រាក់ចំណេញធៀបមូលនិធិភាគទុនិកដល់ -១,៣% និង -៤,១% រៀងគ្នា។

ទោះយ៉ាងនេះក្តី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើនៅរក្សាបានអនុបាតសាធនភាពក្នុងកម្រិត ៣០,៨% លើសកម្រិតកំណត់អប្បបរមាដែលកំណត់ដោយបទប្បញ្ញត្តិប្រុងប្រយ័ត្ន។

ក្រាហ្វ ២១៖ មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ - អនុបាតប្រាក់ចំណេញនិងឥណទានមិនដំណើរការ




## ១.២.២.៣. ប្រតិបត្តិការនៃគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ

ទ្រព្យសកម្មរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ មានចំនួន ១,៤ ទ្រីលានរៀល (៣៤៣,៨ លានដុល្លារអាមេរិក) ដែលរួមចំណែក ០,៤% នៃទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគារនៅកម្ពុជា។ ទោះបីមានចំណែកតូចនៅក្នុងប្រព័ន្ធធនាគារនៅកម្ពុជា គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុបានបន្តរួមចំណែកក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការបង្កើតលទ្ធភាពដល់អតិថិជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម ក្នុងការទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ដូចជា សេវាភតិសន្យាហិរញ្ញវត្ថុលើម៉ូតូ រថយន្ត គ្រឿងយន្តកសិកម្មនិងសំណង់ គ្រឿងសង្ហារិម គ្រឿងអេឡិចត្រូនិក និងបរិក្ខារផ្សេងៗ។

តារាង ៣ ៖ ការវិវឌ្ឍនៃភតិសន្យាហិរញ្ញវត្ថុ

| សូចនាករ | ២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|---|
| ចំនួនគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ | ១៥ | ១៧ | ១៦ | ១៦ | ១៣ |
| ទ្រព្យសកម្មសរុប (គិតជាទ្រីលានរៀល) | ១,៦ | ១,៨ | ២,០ | ២,០ | ១,៤ |
| ភតិសន្យាហិរញ្ញវត្ថុសរុប (គិតជាទ្រីលានរៀល) | ១,៤ | ១,៦ | ១,៨ | ១,៧ | ១,២ |
| មូលនិធិផ្ទាល់សុទ្ធ (គិតជាទ្រីលានរៀល) | ០,៥ | ០,៦ | ០,៦ | ០,៦ | ០,៥ |
| ចំនួនគណនីអតិថិជន | ១០១.០១៨ | ១០៥.៨១១ | ៩៦.២៩១ | ៩០.៣៨២ | ៥១.៣០៧ |
| អនុបាតភតិសន្យាហិរញ្ញវត្ថុមិនដំណើរការ | ៤,៦% | ៥,១% | ៣,៨% | ៥,១% | ៨,៧% |

សមតុល្យភតិសន្យាហិរញ្ញវត្ថុចំនួន ១,២ ទ្រីលានរៀល (៣១៣,២ លានដុល្លារអាមេរិក) ត្រូវបានប្រើប្រាស់ដោយអតិថិជន ដែលមានគណនីសរុបចំនួន ៥១.៣០៧ និងត្រូវបានបែងចែកទៅវិស័យចម្បងៗមួយចំនួន រួមមាន៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៣២,៧% សកម្មភាពគ្រួសារជានិយោជកនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់សេវាកម្ម ២៤,២% សំណង់ ៤,៥% អាជីវកម្មលក់រាយ ៣,៩% ការដឹកជញ្ជូននិងការស្តុកទុក ៣,៥% អាជីវកម្មលក់ដុំ ២,០% សកម្មភាពផ្នែកអចលនទ្រព្យ ១,១% កម្មន្តសាលកម្ម ១,០% សកម្មភាពសេវាកម្មស្នាក់នៅនិងអាហារ ០,៨% និងឥណទានផ្សេងៗ ២៦,៣%។

ក្រាហ្វ ២២៖ ភតិសន្យាហិរញ្ញវត្ថុ - ភតិសន្យាហិរញ្ញវត្ថុតាមប្រភេទជំនួញក្នុងសេដ្ឋកិច្ច




អនុបាតភតិសន្យាហិរញ្ញវត្ថុមិនដំណើរការរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុបានកើនឡើងដល់ ៨,៧% ដែលជាកត្តារួមចំណែកដល់ការធ្លាក់ចុះនៃអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម និង អនុបាតប្រាក់ចំណេញធៀបមូលនិធិភាគទុនិកដល់ -២,៤% និង -៦,៨% រៀងគ្នា។ ទោះជាយ៉ាងនេះក្តី គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុនៅរក្សាបានអនុបាតសាធនភាពក្នុងកម្រិត ៣៥,៣% លើសកម្រិតកំណត់អប្បបរមាដែលតម្រូវដោយបទប្បញ្ញត្តិប្រុងប្រយ័ត្ន។

ក្រាហ្វ ២៣៖ ភតិសន្យាហិរញ្ញវត្ថុ - អនុបាតប្រាក់ចំណេញនិងភតិសន្យាហិរញ្ញវត្ថុមិនដំណើរការ




## ១.២.២.៤. ប្រតិបត្តិការនៃគ្រឹះស្ថានឥណទានជនបទ

គ្រឹះស្ថានឥណទានជនបទ បានបន្តចូលរួមផ្តល់ឥណទានខ្នាតតូច និងតូចបំផុត ជូនដល់ប្រជាជនដែលមានប្រាក់ចំណូលទាប ក្នុងទិសដៅទ្រទ្រង់ការប្រកបអាជីវកម្មលក្ខណៈគ្រួសារ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ។ ទ្រព្យសកម្មរបស់គ្រឹះស្ថានឥណទានជនបទមានចំនួន ២៩៥,២ ប៊ីលានរៀល (៧៣,៣ លានដុល្លារអាមេរិក) ខណៈដែលឥណទានអតិថិជនមានចំនួន ២៤៤,៦ ប៊ីលានរៀល (៦០,៨ លានដុល្លារអាមេរិក) ដោយផ្តល់ជូនទៅកាន់អតិថិជនសរុបចំនួន ១០១.៣២៤ នាក់ តាមរយៈបណ្តាញប្រតិបត្តិការនៅទូទាំងប្រទេស និងមានបុគ្គលិកបម្រើការចំនួន ២.២៦៣ នាក់។ ឥណទានត្រូវបានបែងចែកទៅកាន់វិស័យផ្សេងៗ រួមមាន៖ កសិកម្ម ២៨,៦% គ្រួសារ ២៥,៤% ពាណិជ្ជកម្ម ២១,៣% សេវាកម្ម ៩,៩% សំណង់ ៤,៤% ដឹកជញ្ជូន ០,៧% និងផ្សេងៗ ៩,៧%។

ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ បានបន្តខិតខំយ៉ាងយកចិត្តទុកដាក់ពង្រឹងការត្រួតពិនិត្យគ្រឹះស្ថានឥណទានជនបទ និងមានវិធានការជាបន្តបន្ទាប់ សំដៅធានាការប្រតិបត្តិតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន និងការធ្វើប្រតិបត្តិការអាជីវកម្ម ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រឹះស្ថានឥណទានជនបទ ដើម្បីការពារផលប្រយោជន៍របស់អតិថិជន។

ជារួម គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើរងផលប៉ះពាល់មួយចំនួន រួមមាន៖ ការធ្លាក់ចុះលទ្ធភាពទូទាត់សងរបស់អ្នកខ្ចី ការធ្វើសំវិធានធនបន្ថែមចំពោះឥណទានមិនដំណើរការ ថ្លៃដើមមូលនិធិមានកម្រិតខ្ពស់ និងការថមថយនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ។ យ៉ាងណាមិញ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ នៅតែបន្តអនុលោមបានតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន ជាធរមាន។

### ១.២.៣. ប្រតិបត្តិការនៃគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ៣០ បានទទួលអាជ្ញាបណ្ណ និងគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុចំនួន ៣ បានទទួលលិខិតអនុញ្ញាតផ្តល់សេវាទូទាត់សងប្រាក់ពីធនាគារជាតិនៃកម្ពុជា។ ការប្រើប្រាស់សេវាទូទាត់ឌីជីថលបានរួមចំណែកក្នុងការបង្កើនកម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា និងបានជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការរីកចម្រើននៃសេវាទូទាត់សងប្រាក់ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃចំនួនអតិថិជន ដែលបានចុះឈ្មោះបង្កើតកាបូបអេឡិចត្រូនិកសរុបប្រមាណ ២០,៧ លានគណនី ចំនួនប្រតិបត្តិការរបស់ សេវាទូទាត់សងប្រាក់បានកើនឡើង ៩៩,៣% ដល់ ១,២ ប៊ីលានប្រតិបត្តិការ ហើយទំហំទឹកប្រាក់ក៏បាន កើនឡើង ៥៣,១% ដល់ ១១៦,១ ប៊ីលានដុល្លារអាមេរិក ប្រមាណ ២,៥ ដង នៃផលិតផលក្នុងស្រុកសរុប។

### ១.២.៤. អាជីវកម្មប្តូរប្រាក់

អាជីវកម្មប្តូរប្រាក់សរុបទូទាំងប្រទេសមានចំនួន ៣.៣៣៤ ក្នុងនោះ អាជ្ញាបណ្ណប្រកបអាជីវកម្ម ប្តូរប្រាក់ចំនួន ៤៣ (រាជធានីភ្នំពេញចំនួន ៣៨ និងខេត្តចំនួន ៥) និងលិខិតអនុញ្ញាតប្រកបអាជីវកម្ម ប្តូរប្រាក់ចំនួន ៣.២៩១ (រាជធានីភ្នំពេញចំនួន ៥០ និងខេត្តចំនួន ៣.២៤១)។ ក្នុងឆ្នាំ២០២៤ ធនាគារជាតិ នៃកម្ពុជា បានចេញអាជ្ញាបណ្ណនិងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ថ្មីសរុបចំនួន ៣ ក្នុងនោះ៖ មានអាជ្ញាបណ្ណចំនួន ១ និងលិខិតអនុញ្ញាតចំនួន ២ ខណៈដែលអាជ្ញាបណ្ណនិងលិខិតអនុញ្ញាតប្រកប អាជីវកម្មប្តូរប្រាក់ចំនួន ៧ (អាជ្ញាបណ្ណចំនួន ៥ និងលិខិតអនុញ្ញាតចំនួន ២) ត្រូវបានបញ្ឈប់។

ក្រាហ្វ ២៤៖ អាជីវកម្មប្តូរប្រាក់ - ប្រភេទអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត



ក្រាហ្វ ២៥៖ អាជីវកម្មប្តូរប្រាក់ - ចំនួនលិខិតអនុញ្ញាតនៅតាមបណ្តាខេត្ត




## ១.៣. ប្រតិបត្តិការនៃទីផ្សារអន្តរធនាគារ

ធនាគារជាតិនៃកម្ពុជា បានដាក់ចេញនូវឧបករណ៍សំខាន់ៗ ដូចជា មូលបត្រអាចជួញដូរបាន ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា និងឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី សំដៅចូលរួមអភិវឌ្ឍទីផ្សារអន្តរធនាគារនៅកម្ពុជា។ ទំហំមូលបត្រអាចជួញដូរបានជាប្រាក់រៀលដែលបានបោះផ្សាយកើនឡើង ៥៧,៨% ដល់ ២៦,៨ ទ្រីលានរៀល និងមូលបត្រអាចជួញដូរបានជាប្រាក់ដុល្លារអាមេរិកថយចុះ -២៦,៣% មកត្រឹម ៣,៨ ប៊ីលានដុល្លារអាមេរិក។ ការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ត្រូវបានធ្វើឡើងសរុបចំនួន ៥០ លើក ដោយបានផ្តល់សន្ទនីយភាពសរុបចំនួន ៤,៣ ទ្រីលានរៀល (ប្រមាណ ១,១ លានដុល្លារអាមេរិក) ដែលកើនឡើង ៧៤,១% បើធៀបនឹងឆ្នាំ២០២៣។ គួរកត់សម្គាល់ថា ការបង្កើនរយៈពេលដេញថ្លៃរៀងរាល់សប្តាហ៍ (ចាប់ពីខែសីហា ឆ្នាំ២០២៣) និងការបង្កើនទំហំប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ដែលមានឥណ-ប្រតិទាន ៧ ថ្ងៃ បានជំរុញឱ្យប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាមានការកើនឡើង។ ចំណែកប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី បានជួយបំពេញតម្រូវការសន្ទនីយភាពជាប្រាក់រៀល (ផ្តល់ជូនភ្លាមៗនៅក្នុងថ្ងៃ និងអាចបន្តបានដោយគ្មានការកំណត់ឥណប្រតិទាន) ដោយក្នុងឆ្នាំ២០២៤ ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លីចំនួន ៨៤១ ប៊ីលានរៀល ត្រូវបានផ្តល់ជូនគ្រឹះស្ថានធនាគារចំនួន ២ ក្នុងអត្រាការប្រាក់ ៦%។ ធនាគារជាតិនៃកម្ពុជា បានផ្តល់ការអនុញ្ញាតដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៦ ប្រើប្រាស់ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លី ដែលធានាដោយមូលបត្រអាចជួញដូរបាន និង/ឬ មូលបត្ររដ្ឋ។ នាចុងឆ្នាំ២០២៤ អត្រាការប្រាក់ប្រតិបត្តិការផ្តល់សន្ទនីយភាពរយៈពេលខ្លីត្រូវបានបន្ថយពី ៦% មក ៥,៥% ក្នុងមួយឆ្នាំ ដែលមានលក្ខណៈល្អជាងអត្រាឥណទានវិបារូបន៍ជាដុល្លារអាមេរិក ដែលមានកម្រិត ៦%។

## ២. ការវិវឌ្ឍនៃក្របខ័ណ្ឌត្រួតពិនិត្យនិងបទប្បញ្ញត្តិ

### ២.១. ការពិនិត្យឡើងវិញ និងការដាក់ចេញនូវបទប្បញ្ញត្តិ

ប្រកាស និងសេចក្តីណែនាំមួយចំនួន ត្រូវបានដាក់ចេញដើម្បីពង្រឹងភាពធន់ និងធានាវឌ្ឍនភាពនៅក្នុងប្រព័ន្ធធនាគារ ដូចជា ១/-ប្រកាសស្តីពី អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារ

និងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ២/-ប្រកាសស្តីពី ប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មគ្រីបតូ ៣/-ប្រកាសស្តីពី ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤/-ប្រកាសស្តីពី អនុបាតសន្ទនីយភាពសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៥/-ប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៦/-ប្រកាសស្តីពី ហានិភ័យប្រតិបត្តិការសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៧/-សេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពី ហានិភ័យទីផ្សារសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៨/-សារាចរណែនាំស្តីពី ការប្រគល់ឯកសារសម្គាល់ទ្រព្យធានាជូនអតិថិជនឥណទាន ៩/-សារាចរណែនាំស្តីពី ការលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រួលក្នុងការបើកគណនីសន្សំ និងផ្តល់សេវាហិរញ្ញវត្ថុជូនសហគ្រាសធុនមីក្រូ តូច និងមធ្យម និងបុគ្គលស្វ័យនិយោជន៍ ១០/-សេចក្តីជូនដំណឹងស្តីពី ការទប់ស្កាត់ការប្រើប្រាស់ក្រដាសប្រាក់រៀលក្លែងក្លាយ និង ១១/-សេចក្តីជូនដំណឹងស្តីពី ការទប់ស្កាត់ការប្រើប្រាស់ក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ។

ដើម្បីផ្តល់លទ្ធភាពបន្ថែមឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការបញ្ចេញឥណទាន សំដៅចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជា សម្រេច៖ ១/-បន្តអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ើវេសិន ត្រឹមកម្រិត ១,២៥% រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥ ២/-បន្តអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណត្រឹមកម្រិត ៧% រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥ និង ៣/-អនុញ្ញាតឱ្យរៀបចំឥណទានឡើងវិញជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន តាមរយៈការដាក់ចេញនូវសារាចរណែនាំស្តីពី ការរៀបចំឥណទានឡើងវិញ។ ដោយឡែក ការអនុវត្តប្រកាសនិងសេចក្តីណែនាំពាក់ព័ន្ធនឹងក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុនត្រូវបានពន្យារ រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ ដើម្បីទុកពេលវេលាបន្ថែមជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា។

ទន្ទឹមនេះ ប្រកាសនិងសេចក្តីណែនាំមួយចំនួនក៏កំពុងត្រូវបានរៀបចំ រួមមាន៖ ១/-ប្រកាសពាក់ព័ន្ធក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ២/-ប្រកាសស្តីពី វិធានការបុរេសកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៣/-ប្រកាសស្តីពី ការកំណត់ពិដានអត្រាការប្រាក់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៤/-ប្រកាសស្តីពី ការគួបសរុបផ្នែកបទប្បញ្ញត្តិសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៥/-ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៦/-ប្រកាសស្តីពី ការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និង ៧/-សេចក្តីណែនាំស្តីពី ការវាយតម្លៃទ្រព្យធានាក្នុងគោលបំណងវាយតម្លៃលើអ៊ីមភែរមិន។

បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ការយល់ដឹងពីបទប្បញ្ញត្តិដែលបានដាក់ចេញ និងជំរុញការអនុវត្តឱ្យមានសង្គតិភាព និងប្រសិទ្ធភាព។

## ២.២. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

### ២.២.១. សកម្មភាពនៃការត្រួតពិនិត្យ

ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានពង្រឹងជាបន្តបន្ទាប់ ជាពិសេសក្នុងស្ថានភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចតំបន់និងពិភពលោក ដែលប៉ះពាល់ដល់ដំណើរការនៃទីផ្សារហិរញ្ញវត្ថុអន្តរជាតិនិងនៅប្រទេសកម្ពុជា។ ក្នុងនោះ ការត្រួតពិនិត្យផ្អែកលើហានិភ័យ និងទស្សនៈអនាគតត្រូវបានអនុវត្តចំពោះការងារត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែង ផ្តោតលើការវិភាគស្ថានភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទាំងផ្នែកបរិមាណនិងគុណភាព ដើម្បីកំណត់ឱ្យបានជាមុននូវហានិភ័យនានា និងចាត់វិធានការកែតម្រូវទាន់ពេលវេលា។ បន្ថែមពីនេះ ការត្រួតពិនិត្យក៏រួមបញ្ចូលការធ្វើស្ត្រេសតេស្តលើសូចនាករសំខាន់ៗមួយចំនួន ដូចជា អនុបាតសាធនភាព អនុបាតក្របខ័ណ្ឌសន្ទនីយភាព ជាដើម ដើម្បីវាយតម្លៃលើស្ថានភាពរបស់គ្រឹះស្ថាននីមួយៗ និងប្រព័ន្ធធនាគារទាំងមូល។

ក្នុងឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែងផ្អែកលើផែនការគ្រោងទុកចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ២៦ ក្នុងនោះ ធនាគារពាណិជ្ជចំនួន ៩ ធនាគារឯកទេសចំនួន ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ១ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន ១០ និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុចំនួន ៥ ដោយផ្តោតលើអភិបាលកិច្ច គុណភាពទ្រព្យសកម្ម ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងសន្ទនីយភាព ការត្រួតពិនិត្យផ្ទៃក្នុង និងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន រួមបញ្ចូលទាំងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ ជាងនេះទៅទៀត ធនាគារជាតិនៃកម្ពុជា បានចុះត្រួតពិនិត្យដល់ទីកន្លែងដោយគ្មានការជូនដំណឹងជាមុនចំពោះគ្រឹះស្ថានធនាគារចំនួន ៨ ដើម្បីពិនិត្យលើប្រសិទ្ធភាពនៃការអនុវត្តសារាចរណែនាំស្តីពី ការរៀបចំឥណទានឡើងវិញ។

ជារួម ប្រព័ន្ធធនាគារបន្តរក្សាបានភាពធន់ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃអនុបាតសាធនភាព និងអនុបាតសន្ទនីយភាព និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ទោះយ៉ាងណាគ្រឹះស្ថានមួយចំនួននៅមានចំណុចខ្វះខាតពាក់ព័ន្ធនឹងអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ ការផ្តល់ឥណទានជារូបិយវត្ថុជាតិ និងការអនុវត្តមិនបានពេញលេញតាមអនុសាសន៍។ ការខ្វះខាតទាំងនេះត្រូវបានតាមដានជាប្រចាំ តាមរយៈការវាយតម្លៃលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ប្រចាំត្រីមាសនីមួយៗ ហើយធនាគារជាតិនៃកម្ពុជាក៏បានអនុវត្តវិធានការរដ្ឋបាលមួយចំនួនចំពោះគ្រឹះស្ថានដែលមិនគោរពតាម។

### ២.២.២. ឥណទានរៀបចំឡើងវិញ

ធនាគារជាតិនៃកម្ពុជា ចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារ និងជំរុញវិស័យទេសចរណ៍ក៏ដូចជាជួយសម្រួលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញចំពោះវិស័យទេសចរណ៍ នៅខេត្តសៀមរាប តាមរយៈសេចក្តីជូនដំណឹងចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣។ ក្នុងន័យនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចអនុវត្តការរៀបចំឥណទានឡើងវិញជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ក្នុងរយៈពេល ១២ ខែ ដោយមិនចាំបាច់ធ្វើសំវិធានធនបន្ថែម។ គិតត្រឹមដំណាច់

ឆ្នាំ២០២៤ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានរៀបចំឥណទានឡើងវិញជូនអ្នកខ្ចីចំនួន ៦.១២០ នាក់ ដោយមានសមតុល្យសរុប ៦៤៣,៧ លានរៀល (១៥៩,៩ លានដុល្លារអាមេរិក)។

បន្ថែមលើនេះ ដើម្បីជួយសម្រាលបន្ទុកចំណាយប្រចាំគ្រារបស់អតិថិជនក្នុងការបំពេញកាតព្វកិច្ចសងត្រឡប់ និងជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការបង្កើនលំហូរសាច់ប្រាក់ ធនាគារជាតិនៃកម្ពុជា បានដាក់ចេញបន្ថែមទៀតនូវសារាចរណែនាំ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ស្ដីពី ការរៀបចំឥណទានឡើងវិញ ដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញជូនអតិថិជន។ គិតត្រឹមដំណាច់ឆ្នាំ២០២៤ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានរៀបចំឥណទានឡើងវិញជូនអតិថិជនចំនួន ៨៨.៣១៩ នាក់ ដែលមាន ៩៥.៧៩០ គណនី ជាមួយសមតុល្យសរុប ៧,៤ ទ្រីលានរៀល (១,៨ ប៊ីលានដុល្លារអាមេរិក)។ ជាក់ស្ដែង ការរៀបចំឥណទានឡើងវិញនេះ បានជួយកាត់បន្ថយបន្ទុកចំណាយប្រចាំគ្រារបស់អតិថិជនសរុបប្រមាណ ១៣៥,៦ ប៊ីលានរៀល (៣៣,៧ លានដុល្លារអាមេរិក) ដោយក្នុងនោះបានជួយសម្រាលបន្ទុកចំណាយប្រចាំគ្រាជាមធ្យម ១,៤ លានរៀលក្នុងមួយគណនី។

## ២.៣. ហិរញ្ញវត្ថុប្រកបដោយចីរភាព

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់និងចាត់ទុកកិច្ចការពាក់ព័ន្ធនឹងការជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព ជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពផ្សេងៗទៀត តាមរយៈការចូលរួមចំណែកយ៉ាងសកម្មក្នុងដំណើរការនៃការអភិវឌ្ឍគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ការរៀបចំគំនិតផ្ដួចផ្ដើមនិងកិច្ចពិភាក្សានានា ទាំងក្របខ័ណ្ឌជាតិ តំបន់ និងសកល និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ ក្រសួងនិងស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងវិនិយោគិនបៃតង។

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តសកម្មភាពការងារអាទិភាពមួយចំនួន ដូចជា ១/-ការរៀបចំផែនទីចង្អុលផ្លូវហិរញ្ញវត្ថុបៃតងនៅកម្ពុជា (Cambodian Green Finance Roadmaps) ២/-ការអភិវឌ្ឍប្រព័ន្ធវគ្គកសោស្ត្របៃតងនៅកម្ពុជា (Cambodian Green Finance Taxonomy) ៣/-ការដាក់បញ្ចូលគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច ក្នុងគោលការណ៍ណែនាំស្ដីពី ការវិនិយោគទុនបម្រុងអន្តរជាតិ និងការវិនិយោគលើសញ្ញាបណ្ណបៃតង ៤/-ការចូលរួមវិនិយោគទៅក្នុងសញ្ញាបណ្ណបៃតង ដែលជាផ្នែកមួយនៃការវិនិយោគទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា ៥/-ការលើកទឹកចិត្តផ្នែកបទប្បញ្ញត្តិឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្ដល់ហិរញ្ញប្បទានដល់គម្រោងបៃតង ៦/-ការរៀបចំក្របខ័ណ្ឌវិភាគនិងវាយតម្លៃហានិភ័យពីបម្រែបម្រួលអាកាសធាតុក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ (Climate Risk Assessment and Analysis) ៧/-ការសិក្សាពីលទ្ធភាពនៃការដាក់ចេញសេចក្ដីណែនាំស្ដីពី ការបញ្ជ្រាបហានិភ័យសង្គម និងបរិស្ថាន ក្នុងដំណើរការនៃការគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៨/-ការកសាងសមត្ថភាពនិងលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធហិរញ្ញវត្ថុបៃតង ៩/-កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធនានា និង ១០/-ការសិក្សាស្រាវជ្រាវលើប្រធានបទហិរញ្ញវត្ថុប្រកបដោយចីរភាព និងការប្រែប្រួលអាកាសធាតុ ជាដើម។

គួររំលេចផងដែរថា ក្នុងឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា ក៏បានចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុនៅតំបន់អាស៊ាន ដើម្បីរួមគ្នាធ្វើឱ្យតំបន់នេះក្លាយជាគោលដៅវិនិយោគដ៏ទាក់ទាញសម្រាប់វិនិយោគិនបៃតង។ ធនាគារជាតិនៃកម្ពុជា បានស្នើនូវគំនិតផ្ដួចផ្ដើមថ្មីមួយ សម្រាប់

កិច្ចសហប្រតិបត្តិការរវាងធនាគារកណ្តាល និងក្រសួងហិរញ្ញវត្ថុនៃបណ្តាប្រទេសក្នុងតំបន់ ក្នុងការរៀបចំ និងអនុវត្តនូវប្រតិបត្តិការដោះដូរការវិនិយោគមូលបត្របំណុលប្រកបដោយចីរភាព (Sustainability Bond Investment Swap) ដើម្បីវិនិយោគទុនបម្រុងអន្តរជាតិទៅលើគម្រោងវិនិយោគបៃតងប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលគំនិតផ្តួចផ្តើមនេះត្រូវបានចេញផ្សាយនៅក្នុងទស្សនាវដ្តី **The Banker** កាលពីខែមេសា ឆ្នាំ២០២៤ ក្នុងអត្ថបទ ដែលមានចំណងជើងថា "ការពង្រីកការវិនិយោគទុនបម្រុងអន្តរជាតិរបស់ធនាគារកណ្តាលក្នុងការអភិវឌ្ឍប្រកបដោយចីរភាព"។

ជាទិសដៅ ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តគំនិតផ្តួចផ្តើមសំខាន់ៗបន្ថែមទៀត រួមមាន៖ ១/-បញ្ចប់ផែនទីចង្អុលផ្លូវហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់កម្ពុជា និងស្នើសុំការអនុម័តពីក្រុមការងារហិរញ្ញវត្ថុបៃតង ព្រមទាំងផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តផែនទីចង្អុលផ្លូវនេះ ក្នុងឆ្នាំ២០២៥ ២/-បញ្ចប់ការងារពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធវគ្គីករណ៍សាស្ត្របៃតងនៅកម្ពុជា ដំណាក់កាលទី១ ដែលបានកំណត់រួចជាស្រេចនូវវិស័យអាទិភាពចម្បងចំនួន ៣ សម្រាប់ដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២៥ និងបន្តអភិវឌ្ឍដំណាក់កាលទី២ ដែលនឹងកំណត់វិស័យអាទិភាពចម្បងៗបន្ថែមទៀត ៣/-រៀបចំយន្តការស្តីពី ហិរញ្ញវត្ថុប្រកបដោយចីរភាព ដើម្បីតម្លាភាព និងការទទួលខុសត្រូវ (Reporting and Disclosure Framework) ៤/-ពង្រឹងក្របខ័ណ្ឌវាយតម្លៃ និងការពារហានិភ័យបណ្តាលមកពីបម្រែបម្រួលអាកាសធាតុក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ៥/-ការកសាងសមត្ថភាព និងចំណេះដឹងដល់វិស័យធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធ និង ៦/-សិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធ ក្នុងគោលដៅរៀបចំនិងដាក់ចេញគោលនយោបាយគាំទ្រហិរញ្ញវត្ថុប្រកបដោយចីរភាពនៅកម្ពុជា។

## ២.៤. ការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ

ធនាគារជាតិនៃកម្ពុជា បន្តយកចិត្តទុកដាក់ និងតាមដានជាប្រចាំលើវឌ្ឍនភាពនៃការផ្តល់ហិរញ្ញប្បទានដល់វិស័យអចលនទ្រព្យ ដែលជាវិស័យមួយដើរតួនាទីសំខាន់ក្នុងសេដ្ឋកិច្ច និងមានភាពពាក់ព័ន្ធជិតស្និតជាមួយប្រព័ន្ធធនាគារនៅកម្ពុជា តាមរយៈការផ្តល់ហិរញ្ញប្បទានដល់គម្រោងសាងសង់និងអភិវឌ្ឍន៍អចលនវត្ថុ។ ក្នុងដំណាក់កាលនៃការរាលដាលជំងឺកូវីដ-១៩ វិស័យអចលនទ្រព្យនៅកម្ពុជាក៏បានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ជាពិសេសលទ្ធភាពទូទាត់សងរបស់អ្នកខ្ចីឥណទានពាក់ព័ន្ធវិស័យអចលនទ្រព្យ។ ឥណទានចំពោះវិស័យអចលនទ្រព្យ រួមមាន ឥណទានចំពោះសកម្មភាពអចលនទ្រព្យ សំណង់ និងការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ដែលមានកំណើនសរុប ៤,១%។ ឥណទានចំពោះវិស័យអចលនទ្រព្យមានចំណែក ៣១,៧% នៃសំពៀតឥណទានសរុបរបស់ប្រព័ន្ធធនាគារ ដោយក្នុងនោះ សកម្មភាពអចលនទ្រព្យ ១១,២% សំណង់ ៩,៦% និងការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ១០,៩%។ គួរកត់សំគាល់ថា ការផ្តល់ឥណទានចំពោះការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ត្រូវបានផ្តល់ដល់ក្រុមគ្រួសារសម្រាប់ទិញលំនៅដ្ឋានក្នុងគោលបំណងសម្រាប់រស់នៅ ដែលជាផ្នែកមួយនៃការចូលរួមចំណែកលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។ ការផ្តល់ឥណទានដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំពោះការទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្ន និងទាមទារឱ្យអ្នកខ្ចីបំពេញលក្ខខណ្ឌបានគ្រប់គ្រាន់ ដើម្បីធានាបានការបញ្ចៀស ឬកាត់បន្ថយហានិភ័យទាំងសម្រាប់គ្រឹះស្ថាន និងអតិថិជន។

## ៣. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសមាហរណកម្មក្នុងតំបន់

### ៣.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ

#### ៣.១.១. បច្ចេកវិទ្យាហិរញ្ញវត្ថុ

បន្ទាប់ពីបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តនូវកម្រងសំណួរសម្រាប់វាយតម្លៃការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា ធនាគារជាតិនៃកម្ពុជា ក៏បានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តនូវទម្រង់របាយការណ៍ប្រចាំខែ ស្តីពី ឧបទ្ទវហេតុព័ត៌មានវិទ្យា ដើម្បីរាយការណ៍អំពីករណីឧបទ្ទវហេតុដែលបានកើតមានឡើងក្នុងប្រព័ន្ធធនាគារ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា ក៏បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "របាយការណ៍ប្រចាំខែ ស្តីពី ឧបទ្ទវហេតុព័ត៌មានវិទ្យារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" ដើម្បីផ្តល់ព័ត៌មានបន្ថែម និងណែនាំអំពីរបៀបរាយការណ៍ឱ្យបានត្រឹមត្រូវ ពេញលេញ និងទាន់ពេលវេលា។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា ក៏បានរៀបចំឱ្យមានកិច្ចប្រជុំស្តីពី ការប្រើប្រាស់សេវាធនាគារឌីជីថល និងបច្ចេកវិទ្យាថ្មីៗ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន ២ លើក ផងដែរ ព្រមទាំងបានធ្វើការស្ទង់មតិលើការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ តាមបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីប្រមូលធាតុចូលក្នុងការធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា ឱ្យស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាក្នុងស្រុក តំបន់ ក៏ដូចជាសកលលោក។ ធាតុចូលទាំងអស់នេះ បានរួមចំណែកដ៏សំខាន់ដើម្បីឱ្យធនាគារជាតិនៃកម្ពុជាធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា ឱ្យបានគ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា សម្រាប់ការអនុវត្តនាពេលដ៏ខ្លីខាងមុខនេះ។

ស្របតាមតម្រូវការលើការត្រួតពិនិត្យហានិភ័យបច្ចេកវិទ្យា នាយកដ្ឋានត្រួតពិនិត្យហានិភ័យបច្ចេកវិទ្យានិងនវានុវត្តន៍ ត្រូវបានបង្កើតឡើង ដើម្បីត្រួតពិនិត្យនិងតាមដានការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងតាមដានការអភិវឌ្ឍនៃបច្ចេកវិទ្យា ដែលកំពុងត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធធនាគារទាំងមូល ព្រមទាំងសិក្សាស្រាវជ្រាវពីបញ្ហាប្រឈមនានា ដែលត្រូវយកចិត្តទុកដាក់ និងចាត់វិធានការឆ្លើយតបឱ្យបានទាន់ពេលវេលា។

#### ៣.១.២. ប្រព័ន្ធទូទាត់សងប្រាក់

ប្រព័ន្ធទូទាត់សងប្រាក់បន្តដើរតួនាទីយ៉ាងសំខាន់ និងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការអភិវឌ្ឍ និងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា នៅតែជាអាទិភាពមួយ ដែលធនាគារជាតិនៃកម្ពុជានៅតែបន្តជំរុញ និងលើកទឹកចិត្តជាប្រចាំដើម្បីធានាបានប្រព័ន្ធទូទាត់សងប្រាក់មួយប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាជាសកល។ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ រួមមាន៖ ប្រព័ន្ធផាត់ទាត់ជាតិ ប្រព័ន្ធសេវាទូទាត់រហ័ស ប្រព័ន្ធខេមបូឌានស្វែីច ប្រព័ន្ធបាគង និងប្រព័ន្ធរីថែលផេ។ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើការសាកល្បងប្រព័ន្ធទូទាត់សងប្រាក់រួម ដែលតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដែលបានដាក់ឱ្យដំណើរការកន្លងមកជាច្រកទូទាត់តែមួយក្នុងគោលដៅសម្រួលការធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់ប្រាក់អន្តរគ្រឹះស្ថានទាំងតម្លៃរាយនិងតម្លៃធំ

ដោយមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៤៩ បានដាក់ឱ្យដំណើរការសាកល្បងប្រព័ន្ធ។ បន្ថែមពីលើនេះ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសថៃ ប្រទេសឡាវ ប្រទេសវៀតណាម ប្រទេសម៉ាឡេស៊ី ប្រទេសកូរ៉េខាងត្បូង ក្រុមហ៊ុនអន្តរជាតិយូញៀនផេ និងក្រុមហ៊ុនអាលីផេ ក្នុងគោលបំណងពង្រឹងកិច្ចសហការលើការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ ប្រតិបត្តិការទូទាត់សងប្រាក់និងផ្ទេរប្រាក់ឆ្លងដែនប្រកបដោយបរិយាបន្ន និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ។

បន្ទាប់ពីទទួលបានជោគជ័យក្នុងការដាក់ឱ្យដំណើរការប្រព័ន្ធបាគង ក្នុងឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា នៅបន្តអភិវឌ្ឍប្រព័ន្ធបាគងជាបន្តបន្ទាប់ ដោយបន្ថែមមុខងារថ្មីៗ ដូចជា ១/-ការអភិវឌ្ឍមុខងារចុះឈ្មោះអតិថិជនជាអេឡិចត្រូនិកតាមប្រព័ន្ធបាគង ២/-ការអភិវឌ្ឍសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រមុខងារបាគង (Linking Account) ៣/-ការអភិវឌ្ឍមុខងារខេអេចឃ្យូអរកូតរូបិយប័ណ្ណតែមួយ ៤/-នីតិវិធីដោះស្រាយបណ្ដឹងអតិថិជនប្រព័ន្ធបាគង ៥/-បាគងសម្រាប់ទេសចរ (Bakong Tourist App) និងមុខងារបាគងសម្រាប់ការទូទាត់ឆ្លងដែន (Cross-border Bakong API)។ ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការបឋមកម្មវិធីទូទាត់បាគងទេសចរណ៍ កាលពីខែសីហា ដើម្បីរួមចំណែកលើកកម្ពស់វិស័យទេសចរណ៍នៅកម្ពុជា តាមរយៈការផ្ដល់ជាមធ្យោបាយទូទាត់តាមអេឡិចត្រូនិក ដែលអាចឱ្យទេសចរអន្តរជាតិដែលមកកម្សាន្តនៅកម្ពុជា ធ្វើប្រតិបត្តិការទូទាត់ទំនិញនិងសេវា ប្រកបដោយប្រសិទ្ធភាពនិងភាពងាយស្រួល។ កាលពីខែវិច្ឆិកា ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យដំណើរការកម្មវិធីទូទាត់បាគងទេសចរជាមួយក្រុមហ៊ុនបណ្ដាញប័ណ្ណទូទាត់ម៉ាស្ទ័រកាត ដែលអនុញ្ញាតឱ្យភ្ញៀវទេសចរអន្តរជាតិអាចបញ្ចូលទឹកប្រាក់ក្នុងគណនីបាគង ដោយភ្ជាប់ជាមួយប័ណ្ណទូទាត់ម៉ាស្ទ័រកាត ដែលមានស្រាប់ពីប្រទេសដើមរបស់ខ្លួន ដែលនឹងផ្ដល់បទពិសោធន៍នៃការទូទាត់តាមប្រព័ន្ធឌីជីថលប្រកបដោយភាពងាយស្រួល រហ័ស និងសុវត្ថិភាព ដល់ភ្ញៀវទេសចរដែលធ្វើដំណើរមកកម្ពុជា។

ក្រោមក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុថ្នាក់ជាតិ ធនាគារជាតិនៃកម្ពុជា បានសហការជាមួយ ១/-ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដាក់ចេញនិងផ្សព្វផ្សាយនូវគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០២៣-២០២៨ និង ២/-គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ដើម្បីពិនិត្យ រៀបចំ និងផ្ដល់វឌ្ឍនភាពលើវិធានការគោលនយោបាយនៅក្នុងផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៤-២០២៦ នៃគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

### ៣.១.៣. ការអនុវត្តស្តង់ដាគណនេយ្យ

ធនាគារជាតិនៃកម្ពុជា បានពិនិត្យនិងតាមដានយ៉ាងយកចិត្តទុកដាក់លើការអនុវត្តរបាយការណ៍ត្រួតពិនិត្យទម្រង់ថ្មីចំនួន ៣១ របាយការណ៍ ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ចំពោះគ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដោយដាក់ឱ្យប្រើប្រាស់ជំនួសទម្រង់របាយការណ៍ត្រួតពិនិត្យចាស់ នៅក្នុងប្រព័ន្ធរបាយការណ៍ត្រួតពិនិត្យ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងរៀបចំធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលនឹងជួយកាត់បន្ថយពេលវេលាក្នុងការគួបសរុប ការផ្ទៀងផ្ទាត់ និងការវិភាគទិន្នន័យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ជាមួយគ្នានេះ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវគុណភាពទិន្នន័យ និងពង្រឹងសង្គតិភាពនៃការរៀបចំរបាយការណ៍ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ធនាគារជាតិនៃកម្ពុជា នឹងរៀបចំសិក្ខាសាលាណែនាំបន្ថែមអំពីការរៀបចំរបាយការណ៍ត្រួតពិនិត្យទម្រង់ថ្មី ស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងចែករំលែកអំពីកម្រងសំណួរ-ចម្លើយ ជាពិសេសអំពីកំហុសឆ្គងដែលកើតមានជាញឹកញាប់ក្នុងពេលរៀបចំរបាយការណ៍ទាំងនោះ។

### ៣.១.៤. ការចែករំលែកព័ត៌មានឥណទាន

ប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានសមាជិកចំនួន ១៩៩ ក្នុងនោះ ធនាគារពាណិជ្ជ ៦១ ធនាគារឯកទេស ១០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៦ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១៥ និងគ្រឹះស្ថានឥណទានជនបទ ២៣។

ក្រាហ្វ ២៦៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - គ្រឹះស្ថានជាសមាជិក




សំពៀតឥណទានសរុប ដែលអ្នកផ្តល់ទិន្នន័យបានបញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានចំនួនសរុប ២៣៦,៤ ទ្រីលានរៀល (៥៨,៧ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង៤.៣០០.៣១៣ គណនី ក្នុងនោះ ១/-ឥណទានឯកកត្តបុគ្គលមានចំនួន ២០៥,៥ ទ្រីលានរៀល (៥១,១ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៤.២៩៤.០៦៨ គណនី និង ២/-ឥណទានក្រុមហ៊ុនមានចំនួន ៣០,៩ ទ្រីលានរៀល (៧,៧ ប៊ីលានដុល្លារអាមេរិក) ស្មើនឹង ៦.២៤៣ គណនី។

ក្រាហ្វ ២៧៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - សំពៀតឥណទាន និងចំនួនគណនី



សំពៀតឥណទានសរុបត្រូវបានបញ្ចូលដោយអ្នកផ្តល់ទិន្នន័យនីមួយៗ រួមមាន៖ ធនាគារពាណិជ្ជ ២១១,១ ទ្រីលានរៀល ធនាគារឯកទេស ២,៤ ទ្រីលានរៀល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១៤,៣ ទ្រីលានរៀល គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧,១ ទ្រីលានរៀល គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ១,៤ ទ្រីលានរៀល និងគ្រឹះស្ថានឥណទានជនបទ ៨៤,៥ ប៊ីលានរៀល។

ក្រាហ្វ ២៨៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - សំពៀតឥណទានបែងចែកតាមប្រភេទគ្រឹះស្ថានជាសមាជិក




គ្រឹះស្ថានជាសមាជិកបានចូលប្រើប្រាស់របាយការណ៍ឥណទាន សរុបមានចំនួន ៦,៧ លានប្រតិបត្តិការ ក្នុងនោះ ធនាគារពាណិជ្ជ ៤,២ លានប្រតិបត្តិការ (៦២,៧%) ធនាគារឯកទេស ១៦៩,១ ពាន់ប្រតិបត្តិការ (២,៥%) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ១,៣ លានប្រតិបត្តិការ (១៩,៧%) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៨៧៤,៣ ពាន់ប្រតិបត្តិការ (១៣,១%) គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ៧៤,០ ពាន់ប្រតិបត្តិការ (១,១%) និងគ្រឹះស្ថានឥណទានជនបទ ៥៦,៥ ពាន់ប្រតិបត្តិការ (០,១%)។

ក្រាហ្វ ២៩៖ អ្នកផ្តល់សេវាចែករំលែកព័ត៌មានឥណទាន - ការប្រើប្រាស់របាយការណ៍ឥណទាន




ទន្ទឹមនេះ ទិន្នន័យមូលប្បទានបត្រមិនមានប្រាក់គ្រប់គ្រាន់ក្នុងគណនីដែលផ្តល់ដោយអ្នកផ្តល់ទិន្នន័យក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានសរុបមានចំនួន ៧.៧២៥ ប្រតិបត្តិការ ស្មើនឹង ៤.៦២៩ គណនី និងសមតុល្យសរុបចំនួន ២,៦ ទ្រីលានរៀល (៦៥២,១ លានដុល្លារអាមេរិក)។

ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបានបន្តយកចិត្តទុកដាក់ និងពង្រីកជាបន្តបន្ទាប់ តាមរយៈវឌ្ឍនភាពសំខាន់ៗ រួមមានៈ ១/-ការចុះអនុស្សរណៈយោគយល់គ្រីភាគីរវាងក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (កូរ៉េ) និងធនាគារ JEONBUK ស្តីពី កិច្ចសហការចែករំលែកព័ត៌មានឥណទានឆ្លងដែនរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋកូរ៉េ កាលពីខែឧសភា នៅសាធារណរដ្ឋកូរ៉េ និង ២/-ការដាក់ឱ្យដំណើរការគម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (Financial Transparency Corridor - FTC) រវាងប្រទេសកម្ពុជា និងប្រទេសសិង្ហបុរី កាលពីខែមិថុនា នៅប្រទេសសិង្ហបុរី។ ជាមួយគ្នានេះ សេវាត្រួតពិនិត្យសុខភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ក៏ត្រូវបានអនុញ្ញាតឱ្យតភ្ជាប់ជាមួយកម្មវិធីទូរស័ព្ទរបស់ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អេអឹមខេ ផងដែរ។

លើសពីនេះ សេវាផ្ទៀងផ្ទាត់អចលនទ្រព្យនៅលើគេហទំព័រ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) គឺជាសេវាកម្មថ្មីដែលទើបត្រូវបានសម្ពោធជាផ្លូវការកាលពីខែធ្នូ ដោយប្រើប្រាស់ប្រព័ន្ធកម្មវិធីអន្តរកម្មផ្លាស់ប្តូរទិន្នន័យរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា)។ ព័ត៌មានសំខាន់ៗ ដូចជា ស្ថានភាពអចលនទ្រព្យ ម្ចាស់កម្មសិទ្ធិ ប្រវត្តិជួលអចលនទ្រព្យ និងប្រវត្តិជាប់បន្ទុក នឹងមានបង្ហាញភ្លាមៗនៅក្នុងរបាយការណ៍អចលនទ្រព្យ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចទាញយករបាយការណ៍នេះតាមរយៈប្រព័ន្ធអនឡាញ សម្រាប់ជាមូលដ្ឋានមួយក្នុងការវិភាគ និងវាយតម្លៃឥណទាន ដោយពុំចាំបាច់ចំណាយពេលវេលាក្នុងការស្វែងរក ឬផ្ទៀងផ្ទាត់ព័ត៌មានអចលនទ្រព្យនៅមន្ទីរ ឬក្រសួង។ សមិទ្ធផលនេះ គឺជាកិច្ចសហការរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី និងក្រុមហ៊ុន ហ្វាន់ហ្គាយ ឯ.ក។

ធនាគារជាតិនៃកម្ពុជា ក៏បានអនុញ្ញាតឱ្យក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ដាក់បញ្ចូលលក្ខខណ្ឌនៃការរក្សាទុក និងបង្ហាញពីប្រវត្តិនៃឥណទានរៀបចំឡើងវិញត្រឹមរយៈពេលមួយឆ្នាំប៉ុណ្ណោះ នៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយគិតចាប់ពីថ្ងៃឥណប្រតិទាន។ ការអនុគ្រោះពិសេសនេះ ត្រូវបានធ្វើឡើងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីជួយសម្រាលបន្ទុករបស់អ្នកខ្ចីប្រាក់ក្នុងកាលៈទេសៈ ដែលមានភាពមិនអំណោយផលនៃស្ថានភាពសេដ្ឋកិច្ចកម្ពុជា។

## ៣.២. ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា

ធនាគារជាតិនៃកម្ពុជា នៅតែបន្តយកចិត្តទុកដាក់ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការលើកកម្ពស់ការទទួលបាននិងការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជន។ ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិពាក់ព័ន្ធ ក្នុងការដាក់ចេញនិងអនុវត្តនូវសកម្មភាព យុទ្ធនាការផ្សព្វផ្សាយ កម្មវិធីអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងយន្តការនានា ស្របតាមផែនការសកម្មភាពដែលកំណត់ក្នុងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។

## ប្រអប់
## សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ទិវាសន្សំអាស៊ាន"

សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ទិវាសន្សំអាស៊ាន" ត្រូវបានផ្តួចផ្តើមដោយប្រទេសជាសមាជិកអាស៊ាន និងត្រូវរៀបចំឡើងជារៀងរាល់ឆ្នាំ នៅថ្ងៃទី៣១ ខែតុលា ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់នៃការសន្សំ ដើម្បីឱ្យស្របទៅនឹងការខិតខំរបស់ប្រទេសជាសមាជិកអាស៊ានទាំងអស់ ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុក្នុងតំបន់ និងនៅតាមប្រទេសជាសមាជិកអាស៊ាននីមួយៗ។ សម្រាប់ប្រទេសកម្ពុជា ទិវាសន្សំអាស៊ាននឹងអាចជួយបង្កើនវប្បធម៌សន្សំរបស់ប្រជាពលរដ្ឋ ដែលរួមចំណែកដល់ការកៀរគរប្រាក់សន្សំនៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្លូវការ និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុឱ្យកាន់តែមានភាពប្រសើរឡើង ព្រមទាំងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥។ ធនាគារជាតិនៃកម្ពុជា ដោយមានកិច្ចសហការពីសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា បានរៀបចំកម្មវិធីនេះ តាមរយៈប្រព័ន្ធអនឡាញនិងដោយផ្ទាល់ ដោយមានប្រធានបទសំខាន់ៗ ដូចជា ១/-"សន្សំប្រាក់ឥឡូវនេះដើម្បីអនាគតរបស់អ្នក" ២/-"សន្សំតិចប្រសើរជាងមិនបានសន្សំ" ដែលប្រព្រឹត្តទៅនៅខេត្តសៀមរាប ៣/-"ទន្លាប់សន្សំប្រាក់ដើម្បីអ្នកនិងគ្រួសារអ្នក" ដែលប្រព្រឹត្តទៅនៅខេត្តកំពង់ធំ និង ៤/-"សារៈសំខាន់នៃការសន្សំប្រាក់តាំងពីវ័យកុមារ" ដែលប្រព្រឹត្តទៅនៅខេត្តកំពង់ស្ពឺ។ សិក្ខាសាលានីមួយៗត្រូវបានរៀបចំរយៈពេលមួយថ្ងៃពេញ ដោយមានការចូលរួមពីអភិបាលនៃគណៈអភិបាលខេត្ត/ក្រុង អាជ្ញាធរមូលដ្ឋាន មន្ទីរ និងអង្គភាពពាក់ព័ន្ធក្នុងខេត្ត សហភាពសហព័ន្ធយុវជនកម្ពុជា សមាជិកបង្គោលនៃគម្រោងសុវត្ថិភាពហិរញ្ញវត្ថុសហគមក្នុងខេត្ត លោកគ្រូ-អ្នកគ្រូ សិស្សវិទ្យាល័យនិងមហាវិទ្យាល័យ និងសាធារណជន លើសពី ១០០០ នាក់។ សិក្ខាសាលានីមួយៗបានផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ បានតាំងបង្ហាញអំពីផលិតផល និងសេវាកម្មសន្សំរបស់គ្រឹះស្ថានទទួលប្រាក់បញ្ញើផ្លូវការដល់សាធារណជន ដើម្បីជំរុញឱ្យមានទម្លាប់នៃការសន្សំ និងបង្កើនទំនុកចិត្តក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុជាពិសេសការសន្សំនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ រួមទាំងលើកកម្ពស់ការប្រើប្រាស់និងការសន្សំជាប្រាក់រៀល។

## ៣.២.១. ការអប់រំផ្នែកហិរញ្ញវត្ថុ

### ៣.២.១.១. សិក្ខាសាលាផ្សព្វផ្សាយអំពីវិស័យមីក្រូហិរញ្ញវត្ថុ

នៅក្នុងឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានបន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" នៅតាមបណ្តាខេត្ត និងក្រុង/ស្រុកនានា បានសរុបចំនួន ៦ លើក ក្នុងនោះ សិក្ខាសាលាថ្នាក់ខេត្តចំនួន ២ លើក និង សិក្ខាសាលាថ្នាក់ស្រុកចំនួន ៤ លើក ដោយមានអ្នកចូលរួមសរុបប្រមាណ ១.៥០០ នាក់។ សិក្ខាសាលាទាំងនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ចំណេះដឹងពាក់ព័ន្ធ

នឹងវិស័យធនាគារនិងហិរញ្ញវត្ថុ ជូនដល់អាជ្ញាធរមូលដ្ឋាន ក្នុងគោលដៅលើកកម្ពស់ការយល់ដឹងក្នុងការប្រើប្រាស់សេវាមីក្រូហិរញ្ញវត្ថុ ព្រមទាំងជួយដល់ការរីកចម្រើននៃវិស័យធនាគារនិងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ស្ថិរភាព តម្លាភាព និងកិច្ចការពារផលប្រយោជន៍អ្នកប្រើប្រាស់។ បន្ថែមពីនេះ ក្នុងបរិការណ៍នៃការស្តារសេដ្ឋកិច្ច សិក្ខាសាលាទាំងនេះបានផ្តល់ជាវេទិកាសាធារណៈ សម្រាប់ធនាគារជាតិនៃកម្ពុជា ក្នុងការផ្សព្វផ្សាយអំពីវិធានការនានាដែលបានដាក់ចេញ ដើម្បីសម្រួលដល់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុដែលកំពុងរងផលប៉ះពាល់នៃការធ្លាក់ចុះនៃប្រាក់ចំណូល និងផ្តល់ឱកាសដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋអាចលើកឡើងនូវសំណួរ សំណូមពរ និងបញ្ហាប្រឈមនានាដែលបាននិងកំពុងជួបប្រទះពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុផងដែរ។ រដ្ឋបាលខេត្ត និងក្រុង/ស្រុក អាជ្ញាធរមូលដ្ឋាន និងអ្នកចូលរួមទាំងអស់ បានសាទរយ៉ាងខ្លាំងចំពោះការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" ហើយធនាគារជាតិនៃកម្ពុជា បានប្រមូលជាធាតុចូលសំខាន់ៗជាច្រើន ដែលជាប្រយោជន៍ដល់ការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ ជំរុញបរិយាបន្នហិរញ្ញវត្ថុ លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជន។

### ៣.២.១.២. ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ

ចាប់តាំងពីឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជា បានអនុវត្តការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ធនាគារជាតិនៃកម្ពុជា បានបញ្ចប់ការងារបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅជាមួយក្រសួងអប់រំ យុវជន និងកីឡា ដំណាក់កាលទី១ និងដំណាក់កាលទី២។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំពុងបន្តសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តគម្រោងបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ដំណាក់កាលទី៣។ ផែនការសកម្មភាពសម្រាប់ការអនុវត្តគម្រោងដំណាក់កាលទី៣ រួមមាន៖ ១/-ការរៀបចំសៀវភៅសិស្សសម្រាប់ថ្នាក់ទី៧ ដល់ថ្នាក់ទី១១ លើមុខវិជ្ជាគណិតវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជា ២/-ការរៀបចំសៀវភៅណែនាំសម្រាប់គ្រូថ្នាក់ទី៧ ដល់ថ្នាក់ទី១១ លើមុខវិជ្ជា គណិតវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជា សម្រាប់ជាឯកសារជំនួយស្មារតីក្នុងការបង្រៀនសិស្ស ៣/-ការរៀបចំសៀវភៅលំហាត់ ដើម្បីសិស្សអាចស្វ័យសិក្សា និងបង្កើនចំណេះដឹង ៤/-ការរៀបចំវីដេអូណែនាំ សម្រាប់សិស្សដែលរៀនមិនទាន់ ឬខកខានមិនបានមករៀន នឹងត្រូវចែកជូនសិស្ស ដោយមិនគិតថ្លៃ ៥/-ការបង្រៀនសាកល្បងដោយប្រើប្រាស់ឯកសារនិងសម្ភារៈសិក្សាដែលបានរៀបចំ នៅសាលារៀនគោលដៅចំនួន ១០ និង ៦/-ការវាយតម្លៃនៅពេលបញ្ចប់ឆ្នាំសិក្សា ដែលស្របតាមការធ្វើតេស្តស្តង់ដាកម្មវិធីសម្រាប់ការវាយតម្លៃនិស្សិតអន្តរជាតិ។

### ៣.២.១.៣. ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី

ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី បានបន្តរួមគ្នាអនុវត្តការងារលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី ដោយកាលពីខែឧសភា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពី "ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី" ក្នុងគោលបំណងបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ដែលមានរយៈពេលអនុវត្ត ៥ ឆ្នាំ សំដៅលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី តាមរយៈការបញ្ជ្រាបចំណេះដឹងផ្នែក

ហិរញ្ញវត្ថុ និងហិរញ្ញវត្ថុឌីជីថល ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច និងការពង្រីកភាពជាដៃគូក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី។ អនុស្សរណៈយោគយល់នេះនឹងអនុញ្ញាតឱ្យភាគីទាំងពីរបន្តរួមគ្នាសម្រេចនូវគោលដៅកំណត់ក្នុងយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ និងយុទ្ធសាស្ត្រនារីរតនៈ ទី៦ ឆ្នាំ២០២៤-២០២៨ ផងដែរ។

### ៣.២.១.៤. យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយៈ តក់ៗពេញបំពង់"

ក្នុងការអនុវត្ត យុទ្ធនាការ "តោះ! និយាយពីលុយៈ តក់ៗពេញបំពង់" ក្នុងដំណាក់កាលទី២ ជំហានទី២ ធនាគារជាតិនៃកម្ពុជា និងអង្គការ Good Return បានសហការរៀបចំកម្រងរឿងអប់រំខ្លីពាក់ព័ន្ធនឹងចំណេះដឹងក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ក្រោមខ្លឹមសារអប់រំទាក់ទងនឹងលក្ខខណ្ឌនៃកិច្ចសន្យាឥណទានក្នុងការបង់ផ្តាច់ឥណទានមុនកាលកំណត់ និងហានិភ័យនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ។ ទន្ទឹមនេះ ក្រុមការងារកំពុងរៀបចំ Comic Book ចំនួន ២ ក្រោមចំណងជើង "គិតមុនគូរ" និង "គួរពិចារណា" និងកំពុងធ្វើតេស្តសាកល្បងចំពោះសាធារណជនទូទៅ ដើម្បីទទួលបានមតិយោបល់ និងកែសម្រួលមុននឹងផ្សព្វផ្សាយជាសាធារណៈ។

### ៣.២.១.៥. គម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍"

ធនាគារជាតិនៃកម្ពុជា ក្រោមកិច្ចសហការពីសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមធនាគារនៅកម្ពុជា អង្គការ Cerise+SPTF អង្គការ ADA និង ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី បានបន្តអនុវត្តគម្រោង "ការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍" ក្នុងដំណាក់កាលដំបូងនៅក្នុងឃុំចំនួន ៤ រួមមានៈ ឃុំត្បូងក្រពើក្នុងស្រុកសន្ទុក នៃខេត្តកំពង់ធំ ឃុំស្នំក្រពើក្នុងស្រុកគងពិសី នៃខេត្តកំពង់ស្ពឺ ឃុំពោធិរាជក្នុងស្រុកស្វាយជ្រំ នៃខេត្តស្វាយរៀង និងឃុំវត្តតាមិមក្នុងស្រុកសង្កែ នៃខេត្តបាត់ដំបង ដោយផ្តោតសំខាន់លើការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ បង្កើនភាពអង់អាចរបស់អ្នកប្រើប្រាស់ និងពង្រឹងកិច្ចការពារអតិថិជន។ គម្រោងនេះមានគោលដៅពង្រឹងសុវត្ថិភាពក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ និងជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការនៅតាមសហគមន៍ ដែលស្របទៅនឹងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ គិតត្រឹមឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា និងដៃគូសហការ សម្រេចបានសមិទ្ធផលជាច្រើន រួមមានៈ ១/-ការជ្រើសរើសជនបង្គោលនិងអ្នកសម្របសម្រួលតាមសហគមន៍ ២/-ការរៀបចំសៀវភៅមេរៀនសម្រាប់ការបណ្តុះបណ្តាលចំនួន ៥ មេរៀន ៣/-ការរៀបចំវគ្គបណ្តុះបណ្តាលជូនជនបង្គោល និងអ្នកសម្របសម្រួលតាមសហគមន៍ ៤/-ការរៀបចំ និងបោះពុម្ពខិត្តប័ណ្ណស្តីពីយន្តការបណ្តឹងតវ៉ាសម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ ហើយបានផ្សព្វផ្សាយនៅតាមឃុំគោលដៅ ៥/-ការរៀបចំ និងបោះពុម្ពផ្ទាំងបញ្ជីឈ្មោះ និងលក្ខណៈផលិតផលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្លូវការ ដែលមានប្រតិបត្តិការក្នុងឃុំគោលដៅនីមួយៗ ព្រមទាំងបានបិទផ្សព្វផ្សាយនៅតាមសាលាឃុំ និងច្រកចេញ-ចូលតែមួយរបស់ឃុំ និង ៦/-រៀបចំវគ្គបណ្តុះបណ្តាលបន្ត ដោយជនបង្គោល និងអ្នកសម្របសម្រួលតាមសហគមន៍នៅតាមឃុំគោលដៅនីមួយៗ។

### ៣.២.២. កិច្ចការពារអតិថិជន

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងបន្តពង្រឹងយន្តការគ្រប់គ្រងនិងដោះស្រាយបណ្ដឹងរបស់អតិថិជន ដែលប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តាមរយៈលេខទូរស័ព្ទហាតឡាញរបស់ធនាគារជាតិនៃកម្ពុជា (ទីស្នាក់ការកណ្ដាលចំនួន ៥ ខ្សែ និងសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្តចំនួន ២១ ខ្សែ) ឱ្យកាន់តែមានប្រសិទ្ធភាព ទាន់ពេលវេលា និងមានសង្គតិភាព ដើម្បីធានាពីកិច្ចការពារអតិថិជន។ គិតត្រឹមដំណាច់ឆ្នាំ២០២៤ មន្ត្រីទទួលបន្ទុកហាតឡាញធនាគារជាតិនៃកម្ពុជា បានទទួលបណ្ដឹងនិងការសាកសួរព័ត៌មានសរុបចំនួន ៤.៣០១ ករណី ដោយក្នុងនោះ សម្រាប់ឆ្នាំ២០២៤ មានចំនួន ៤៥៥ ករណី ដែលនៅស្នាក់ការកណ្ដាលមានចំនួន ២៨១ ករណី និងនៅតាមសាខាធនាគារជាតិនៃកម្ពុជា រាជធានី-ខេត្តមានចំនួន ១៧៤ ករណី។ បណ្ដឹងនិងការសាកសួរព័ត៌មានទាំងនេះពាក់ព័ន្ធនឹងៈ ១/-ការបង់ផ្ដាច់ឥណទានមុនកាលកំណត់ ២/-ការដកទ្រព្យធានាឥណទាន ៣/-ការរៀបចំឥណទានឡើងវិញ ៤/-ការកែប្រែព័ត៌មានក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ៥/-ការបន្ធូរបន្ថយប្រាក់ពិន័យ ៦/-ការដាក់ទ្រព្យធានា និងការធានាឥណទាន ៧/-ការផ្ទេរប្រាក់តាមប្រព័ន្ធឌីជីថលមិនបានសម្រេច ៨/-ការប្រើប្រាស់កម្ចីក្រៅផ្លូវការ និង ៩/-ការឆបោកតាមប្រព័ន្ធឌីជីថល។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា ក៏បានបន្តយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកហាតឡាញ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការផ្ដល់ចម្លើយ និងដំណោះស្រាយដែលត្រឹមត្រូវចំពោះរាល់សំណួរ ដែលទទួលបានតាមលេខទូរស័ព្ទហាតឡាញ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា កំពុងពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនឹងកិច្ចការពារអតិថិជនក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ ដោយបាននិងកំពុងសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ក្នុងការធ្វើបច្ចុប្បន្នកម្មប្រកាសស្ដីពី ការដោះស្រាយបណ្ដឹងអតិថិជនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីឱ្យស្របតាមច្បាប់ស្ដីពី កិច្ចការពារអ្នកប្រើប្រាស់ និងការរីកចម្រើននៃប្រព័ន្ធធនាគារនៅកម្ពុជា។

## ៤. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ និងកិច្ចសហប្រតិបត្តិការ

### ៤.១. ការកសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យ

ធនាគារជាតិនៃកម្ពុជា បន្តកសាងសមត្ថភាពរបស់មន្ត្រីត្រួតពិនិត្យ តាមរយៈការលើកទឹកចិត្តដល់មន្ត្រីគ្រប់រូបក្នុងការចូលរួមសិក្សាវគ្គជំនាញត្រួតពិនិត្យតាមប្រព័ន្ធអនឡាញ FSI Connect ដែលរៀបចំដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ ដើម្បីទទួលបានមូលដ្ឋានចំណេះដឹងពាក់ព័ន្ធការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្រាប់ការអនុវត្តការងារត្រួតពិនិត្យផ្អែកលើហានិភ័យ និងអនុលោមតាមគោលការណ៍ស្នូលបាសែលស្ដីពី ការត្រួតពិនិត្យធនាគារប្រកបដោយប្រសិទ្ធភាព។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជា បានចាត់តាំងមន្ត្រីត្រួតពិនិត្យឱ្យចូលរួមវគ្គសិក្សាតាមប្រព័ន្ធអនឡាញស្ដីពី ការត្រួតពិនិត្យ និងបទប្បញ្ញត្តិ ដែលសហការរៀបចំដោយធនាគារសម្រាប់ការទូទាត់អន្តរជាតិ និងមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីមានឱកាសស្វែងយល់ឱ្យកាន់តែស៊ីជម្រៅលើការងារត្រួតពិនិត្យ តាមរយៈការពិភាក្សា និងផ្លាស់ប្ដូរបទពិសោធន៍ជាមួយសិក្ខាកាមមកពីបណ្ដាស្ថាប័នជាអាជ្ញាធរត្រួតពិនិត្យជុំវិញពិភពលោក។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានរៀបចំវគ្គបណ្តុះបណ្តាល និងវគ្គចែករំលែកចំណេះដឹងផ្ទៃក្នុង ជាបន្តបន្ទាប់អំពីច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យធនាគារនិងហិរញ្ញវត្ថុ ដោយក្នុងនោះ ធនាគារជាតិនៃកម្ពុជា បានសហការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រៀបចំសិក្ខាសាលាប្រមូលផាតុចូលស្តីពី បញ្ហាប្រឈមផ្នែកច្បាប់ពាក់ព័ន្ធនឹងការអនុវត្តក្នុងវិស័យធនាគារ ដែលរួមបញ្ចូលប្រធានបទសំខាន់ចំនួន ៣ រួមមាន៖ ១/-ការអនុវត្តហ៊ីប៉ូតែក ២/-ការប្រើប្រាស់មូលប្បទានបត្រ និង ៣/-ការអនុវត្តជាក់ស្តែងអំពីសន្តតិកម្ម។ បន្ថែមលើនេះ ការចែករំលែកចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងនវានុវត្តន៍បច្ចេកវិទ្យា និងបច្ចេកវិទ្យាហិរញ្ញវត្ថុ រួមបញ្ចូលប្រធានបទសំខាន់ៗ ដូចជា ទ្រព្យសកម្មឌីជីថល សន្តិសុខសាយប័រ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងទិន្នន័យធំ ជាដើម ដើម្បីពង្រឹងចំណេះជំនាញ ទាំងផ្នែករឹង និងផ្នែកទន់ សំដៅអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីត្រួតពិនិត្យឱ្យមានគុណវុឌ្ឍិពេញលេញក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព ស្របតាមដំណើរការនៃការអភិវឌ្ឍយ៉ាងរហ័សនៃប្រព័ន្ធធនាគារនៅកម្ពុជា ក្នុងតំបន់ និងសកលលោក។

ក្រៅពីវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ និងវគ្គចែករំលែកចំណេះដឹងផ្ទៃក្នុង មន្ត្រីត្រួតពិនិត្យក៏បានចូលរួមដោយផ្ទាល់ក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំពាក់ព័ន្ធ ក្នុងប្រទេសនិងក្រៅប្រទេស ដែលរៀបចំដោយស្ថាប័នអន្តរជាតិ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងមជ្ឈមណ្ឌលស៊ាសិន ជាដើម។

## ៤.២. កិច្ចសហប្រតិបត្តិការជាតិ

### ៤.២.១. អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងសហការយ៉ាងជិតស្និតជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្នុងការចែករំលែកព័ត៌មានជាប្រចាំស្តីពីសាវតាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានប្រជុំជាប្រចាំជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីពិភាក្សាអំពីបញ្ហាប្រឈម យន្តការដោះស្រាយ និងផែនការអនុវត្ត ក៏ដូចជាសហការដាក់ទណ្ឌកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់ បទប្បញ្ញត្តិ ឬអនុសាសន៍នានាពាក់ព័ន្ធនឹងការអនុវត្តតាមកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ជាងនេះទៅទៀត ធនាគារជាតិនៃកម្ពុជាក៏បានបញ្ចប់ការវាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី២ ស្តីពី ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយទទួលបន្ទុកដឹកនាំក្រុមការងារចំនួន ៤ រួមមាន៖ ១/-ក្រុមការងារវាយតម្លៃវិស័យធនាគារ ២/-ក្រុមការងារវាយតម្លៃវិស័យហិរញ្ញវត្ថុផ្សេងៗក្រៅពីធនាគារ ៣/-ក្រុមការងារវាយតម្លៃផលិតផលសម្រាប់ជំរុញបរិយាបន្នហិរញ្ញវត្ថុ និង ៤/-ក្រុមការងារវាយតម្លៃគ្រឹះស្ថានផ្តល់សេវាទ្រព្យសកម្មនិម្មិត។

### ៤.២.២. អគ្គស្នងការដ្ឋាននគរបាលជាតិ

ក្នុងការចូលរួមទប់ស្កាត់សកម្មភាពប្រតិបត្តិការធនាគារមិនស្របច្បាប់ និង/ឬ មិនមានការអនុញ្ញាត ធនាគារជាតិនៃកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ បាននិងកំពុង ១/-ស្រាវជ្រាវ តាមដាន កំណត់មុខសញ្ញា និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការធនាគារមិនស្របច្បាប់ ឬ មិនមានការអនុញ្ញាត ២/-ជូនដំណឹង និងសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីរៀបចំផែនការ ឬ វិធានការ

ដោះស្រាយទៅលើក្រុមហ៊ុន ឬ បុគ្គលដែលធ្វើប្រតិបត្តិការធនាគារដោយគ្មានច្បាប់អនុញ្ញាត ៣/-សហការ ឬ ចុះប្រតិបត្តិការដល់ទីកន្លែងជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីប្រមូលភស្តុតាង និងចាត់វិធានការចំពោះក្រុមហ៊ុន ឬ បុគ្គលល្មើសច្បាប់ ៤/-រាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តមុខងារភារកិច្ចខាងលើជូនថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា និង ៥/-បំពេញមុខងារនិងភារកិច្ចផ្សេងៗទៀតដែលថ្នាក់នាំធនាគារជាតិនៃកម្ពុជាប្រគល់ជូន។ ធនាគារជាតិនៃកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិ បានចេញសេចក្តីថ្លែងការណ៍រួម ក្រោមបរិបទការបង្ក្រាបសកម្មភាពផ្សព្វផ្សាយនិងផ្តល់ឥណទានដោយខុសច្បាប់ សំដៅចូលរួមទប់ស្កាត់ឱ្យទាន់ពេលវេលានូវបទល្មើសនានា ដែលអាចបង្កជាហានិភ័យចំពោះគ្រឹះស្ថាន អតិថិជន និងប្រព័ន្ធធនាគារទាំងមូល។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា បានសហការក្នុងការទប់ស្កាត់ក្រុមហ៊ុនខុសច្បាប់ដែលបានផ្សព្វផ្សាយលើគេហទំព័រហ្វេសប៊ុក និងបណ្តាញសង្គមផ្សេងទៀត អំពីការផ្តល់សេវាឥណទាន និងសេវាធនាគារផ្សេងទៀត ដែលមិនមានច្បាប់អនុញ្ញាត។

### ៤.២.៣. កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ

ធនាគារជាតិនៃកម្ពុជា បានទទួលការស្នើសុំកិច្ចសហការសម្របសម្រួលក្នុងការស្រាវជ្រាវព័ត៌មានគណនីអតិថិជន ការបង្កកនិងការលើកលែងការបង្កកគណនី សរុបចំនួន ២៣៣ ករណី ក្នុងនោះ ក្រសួងយុត្តិធម៌ និងសាលាដំបូងរាជធានី-ខេត្ត ១០៦ ករណី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គ-នាយកដ្ឋានពន្ធដារ ៥៨ ករណី ក្រសួងមហាផ្ទៃ ៦១ ករណី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៣ ករណី និងស្ថាប័នផ្សេងៗ ៤ ករណី។ ក្នុងចំណោមសំណើសុំកិច្ចសហការទាំងនេះ ធនាគារជាតិនៃកម្ពុជា បានសម្របសម្រួលក្នុងការស្រាវជ្រាវព័ត៌មានគណនីអតិថិជនចំនួន ១៩២ ករណី ការបង្កកគណនីចំនួន ៨៨ ករណី ការលើកលែងការបង្កកគណនីចំនួន ៣៩ ករណី និងករណីផ្សេងៗចំនួន ៤ ករណី។ ក្រៅពីនេះ សំណើសុំកិច្ចសហការចំនួន ៨២២ ករណីទៀត ត្រូវបានស្ថាប័នតុលាការ និងអគ្គស្នងការដ្ឋាននគរបាលជាតិស្នើសុំអនុវត្តដោយផ្ទាល់ទៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

### ៤.២.៤. សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា នៅតែបន្តចូលរួមចំណែកជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុ លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជនឱ្យកាន់តែប្រសើរឡើង តាមរយៈការអនុវត្តគំនិតផ្តួចផ្តើម យុទ្ធនាការ និងសកម្មភាពនានា ដែលចូលរួមបង្កើនការយល់ដឹង ការទទួលបាន និងការប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព បរិយាបន្ន និងចីរភាព។ ធនាគារជាតិនៃកម្ពុជា ក៏បានគាំទ្រដល់សមាគមទាំងពីរ ដោយបានអនុញ្ញាតឱ្យគណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុនៃសមាគមទាំងពីរ និងគ្រឹះស្ថានដែលជាសមាជិកអាចប្រើប្រាស់ឧបករណ៍ផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីផ្សព្វផ្សាយបន្តនៅក្នុងសិក្ខាសាលា យុទ្ធនាការ និងកម្មវិធីផ្សព្វផ្សាយនានារបស់គណៈ-កម្មាធិការ សមាគម និងគ្រឹះស្ថានផងដែរ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា តាមរយៈសមាគម តែងតែជំរុញនិងលើកទឹកចិត្តឱ្យគ្រប់គ្រឹះស្ថានដែលជាសមាជិក បន្តចូលរួមក្នុងសកម្មភាពបរិយាបន្នហិរញ្ញវត្ថុ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ក្រមប្រតិបត្តិទីផ្សារ និងកិច្ចការពារអតិថិជន ព្រមទាំងបន្តរួមចំណែកក្នុងដំណើរការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។

## ៤.៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ៤.៣.១. គណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ

ធនាគារជាតិនៃកម្ពុជា បានសហការជាមួយគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ លើគម្រោង "ការជំរុញសហគ្រិនភាពរបស់ស្ត្រី (Catalyzing Women's Entrepreneurship)" ដោយបានរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់ស្ត្រី និងសហគ្រិនជាស្ត្រីក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំរុញការទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ។ ភាគីទាំងពីរបានសហការរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់សហគ្រិនជាស្ត្រីពាក់ព័ន្ធនឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ហិរញ្ញវត្ថុឌីជីថល ការកត់ត្រាចំណូល-ចំណាយក្នុងអាជីវកម្ម និងការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់សេវាហិរញ្ញវត្ថុនិងបទល្មើសហិរញ្ញវត្ថុ។ ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិ បានបន្តអនុវត្តគម្រោង "ការជំរុញសហគ្រិនភាពរបស់ស្ត្រី" ដោយបានរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់សហគ្រិនជាស្ត្រីក្នុងខេត្តចំនួន ២ បន្ថែមទៀតរួមមាន៖ ខេត្តកំពង់ចាម និងខេតក្រចេះ ក្នុងគោលដៅលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងហិរញ្ញវត្ថុឌីជីថល ពង្រឹងការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងបទល្មើសហិរញ្ញវត្ថុ ពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ និងពង្រីកលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានអ្នកចូលរួមសរុបប្រមាណ ៣៦០ នាក់។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ចសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិករបស់អង្គការសហប្រជាជាតិបានចុះអនុស្សរណៈនៃកិច្ចព្រមព្រៀងស្តីពី ការអភិវឌ្ឍផែនទីចង្អុលផ្លូវហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ក្នុងគោលដៅកាត់បន្ថយការផ្តល់ហិរញ្ញប្បទានដែលប៉ះពាល់ដល់បរិស្ថាន ព្រមទាំងចូលរួមទប់ស្កាត់បញ្ហាប្រែប្រួលអាកាសធាតុ និងធានាការអភិវឌ្ឍប្រកបដោយចីរភាព។ ការងាររៀបចំផែនទីចង្អុលផ្លូវហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា កំពុងត្រូវបានអនុវត្តដោយធនាគារជាតិនៃកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

### ៤.៣.២. សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជា បានសហការជាមួយសហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ អភិវឌ្ឍក្របខ័ណ្ឌប្រមូលទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមភេទសម្រាប់ធនាគារជាតិនៃកម្ពុជា ដើម្បីអាចកំណត់ចន្លោះខ្វះខាតនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុបែងចែកតាមភេទឱ្យកាន់តែមានប្រសិទ្ធភាពនិងត្រឹមត្រូវ ដើម្បីជាមូលដ្ឋានក្នុងការដាក់ចេញនូវគោលនយោបាយ ដែលនឹងជួយជំរុញកម្រិតបរិយាបន្នហិរញ្ញវត្ថុរបស់ស្ត្រី។ ទម្រង់របាយការណ៍ប្រមូលទិន្នន័យបរិយាបន្នហិរញ្ញវត្ថុបែងចែកតាមភេទ ត្រូវបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត និងរាយការណ៍មកធនាគារជាតិនៃកម្ពុជា ជារៀងរាល់ត្រីមាស ចាប់តាំងពីត្រីមាសទី៣ ឆ្នាំ២០២៤ នេះតទៅ។

### ៤.៣.៣. សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

ធនាគារជាតិនៃកម្ពុជា បានសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ក្នុងការអភិវឌ្ឍទីផ្សារខ្សែច្រវ៉ាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុ ដើម្បីពង្រឹងលទ្ធភាពដល់ការទទួលបានហិរញ្ញប្បទានសម្រាប់អាជីវកម្ម

នៅកម្ពុជា ជាពិសេស សហគ្រាសធុនតូច និងមធ្យម ព្រមទាំងពង្រឹងខ្សែច្រវ៉ាក់ផលិតកម្មនៅកម្ពុជា។ ក្នុងឆ្នាំ២០២៤ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងសមាគមធនាគារនៅកម្ពុជាបានរៀបចំសៀវភៅណែនាំស្តីពី សេវា Factoring ដើម្បីផ្តល់ជាគោលការណ៍ណែនាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ជាមួយគ្នានេះ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបានរៀបចំវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ដល់មន្ត្រីនៃអគ្គនាយកដ្ឋានត្រួតពិនិត្យ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីធ្វើការសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់ពីសេវា Factoring ការផ្តល់ហិរញ្ញប្បទានដែលធានាដោយចលនវត្ថុ និងការអភិវឌ្ឍទីផ្សារខ្សែច្រវ៉ាក់ផ្គត់ផ្គង់ហិរញ្ញវត្ថុជាដើម។ បន្ថែមពីនេះ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ក៏បាននិងកំពុងគាំទ្រដល់ធនាគារជាតិនៃកម្ពុជា ក្នុងការពង្រឹងកិច្ចការពារអតិថិជនដែលប្រើប្រាស់សេវាហិរញ្ញវត្ថុ តាមរយៈ ១/-ការផ្តល់ជំនួយបច្ចេកទេសក្នុងការរៀបចំបទប្បញ្ញត្តិ និងការត្រួតពិនិត្យពាក់ព័ន្ធនឹងកិច្ចការពារអតិថិជន ២/-ការសហការជាមួយសមាគម ភាគីពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការបង្កើនសមត្ថភាពបុគ្គលិក និងពង្រឹងស្វ័យនិយ័តកម្ម និង ៣/-ការជំរុញឱ្យមានយន្តការឯករាជ្យក្នុងការដោះស្រាយបណ្តឹងនិងវិវាទក្នុងវិស័យធនាគារ ឬ រៀបចំបង្កើតមជ្ឈមណ្ឌលសម្រាប់អតិថិជនហិរញ្ញវត្ថុ (Financial Consumer Center)។

### ៤.៣.៤. សមាគមឥណទានកសិកម្មនិងជនបទ សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក

ក្នុងនាមជាសមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគមឥណទានកសិកម្ម និងជនបទសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ធនាគារជាតិនៃកម្ពុជាបានទទួលរៀបចំវេទិកាគោលនយោបាយថ្នាក់តំបន់ ស្តីពីការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសកសិកម្មធុនតូច និងមធ្យម ដើម្បីជំរុញការអភិវឌ្ឍក្នុងប្រទេស និងរៀបចំកិច្ចប្រជុំគណៈកម្មការប្រតិបត្តិរបស់សមាគមឥណទានកសិកម្មនិងជនបទ សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងខែសីហា នៅខេត្តសៀមរាប។ កម្មវិធីខាងលើនេះបានផ្តល់ឱកាសដល់អ្នកចូលរួមប្រមាណ ៩០ រូប មកពីធនាគារកណ្តាល ស្ថាប័នរៀបចំគោលនយោបាយ ស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងយល់ និងពិភាក្សាអំពីគោលនយោបាយសម្រាប់កាត់បន្ថយគម្លាតហិរញ្ញប្បទាន គាំទ្រដល់ការអភិវឌ្ឍសហគ្រាសកសិកម្មធុនតូច និងមធ្យម និងតួនាទីនិងយន្តការស្ថាប័ន ក្នុងការផ្តល់ហិរញ្ញប្បទានបន្ថែមដល់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងបទពិសោធន៍និងការអនុវត្តជាក់ស្តែង។

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ១ ទិន្នន័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ឆ្នាំ២០២៤ (នៅផ្នែកភាសាអង់គ្លេស)

ឧបសម្ព័ន្ធ ២ ប្រព័ន្ធធនាគារនៅកម្ពុជា

ឧបសម្ព័ន្ធ ៣ បញ្ជីឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ៤ បញ្ជីឈ្មោះគ្រឹះស្ថានឥណទានជនបទដែលត្រូវបានបញ្ឈប់ប្រតិបត្តិការក្នុងឆ្នាំ២០២៤

ឧបសម្ព័ន្ធ ៥ បណ្តាញព័ត៌មានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ពីឆ្នាំ២០២០-២០២៤

ឧបសម្ព័ន្ធ ៦ បញ្ជីលេខទូរស័ព្ទទំនាក់ទំនងអំពីចម្ងល់ និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ

## ឧបសម្ព័ន្ធ ២

# ប្រព័ន្ធធនាគារនៅកម្ពុជា

### ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

**ធនាគារជាតិនៃកម្ពុជា**
**(ធនាគារកណ្តាល)**

## ៥៩ ធនាគារពាណិជ្ជ

### ១១ សាខាធនាគារបរទេស

១. ធនាគារ ពាណិជ្ជទីមួយ សាខាភ្នំពេញ
២. ធនាគារ ក្រុងថៃ ចំកាត់ មហាជន សាខាភ្នំពេញ
៣. ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ
៤. ធនាគារ មេហ្គា អ៊ិនធើណេសិនណល ខមមើសល ប៊ែង ខូអិលធីឌី សាខាភ្នំពេញ
៥. ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ
៦. ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ
៧. ធនាគារ បាងកក មហាជន ទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា
៨. សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ)
៩. សាខាធនាគារ មីហ្ស៊ូហូ អិលធីឌី
១០. ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម (អាហ្គ្រីប៊ែង) សាខាកម្ពុជា
១១. សាខាធនាគារ អ៊ិនដាសស្ទ្រៀល ប៊ែង អហ្វ ខូរៀ "ភ្នំពេញ"

### ២៨ ធនាគារបង្កើតឡើងក្នុងស្រុក

១. ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
២. ធនាគារ កម្ពុជាអាស៊ី ចំកាត់
៣. ធនាគារ កាណាឌីយ៉ា ក.អ
៤. ធនាគារ វឌ្ឍនៈ
៥. ធនាគារ អេស៊ីលីដា ភីអិលស៊ី
៦. ធនាគារ ស្ថាបនា ភីអិលស៊ី
៧. ធនាគារ ប៊ូយ៉ុង ខ្មែរ
៨. ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក
៩. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
១០. ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក
១១. ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក
១២. ធនាគារ ព្រីនស៍ ម.ក
១៣. ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក
១៤. ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក
១៥. ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក
១៦. ធនាគារ ផេនដា ខមមើសល ប៊ែង ម.ក
១៧. ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម
១៨. ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា ម.ក "ធ.ស.ក"
១៩. ធនាគារពាណិជ្ជ អាល់ហ្វា ម.ក
២០. ធនាគារ អេស ប៊ី អាយ លី ហ្វូរ ម.ក
២១. ធនាគារ ភីក វេល ម.ក
២២. ធនាគារ វីង (ខេមបូឌា) ម.ក
២៣. ធនាគារ ហេងហ៊ី (ខេមបូឌា) ខមមើសល ប៊ែង ម.ក
២៤. ធនាគារ អូរៀនថល ម.ក
២៥. ធនាគារ ប្រ៊ីដ ម.ក
២៦. ធនាគារ ស៊ីស៊ីយូ ខមមើសល ប៊ែង ម.ក
២៧. ធនាគារ ហេង ហ្វឹង (ខេមបូឌា) ម.ក
២៨. ធនាគារ អាយភីយូ ស៊ី ប៊ែង (ខេមបូឌា) ម.ក

### ២០ បុត្តសម្ព័ន្ធធនាគារបរទេស

១. ធនាគារ កម្ពុជាពាណិជ្ជ ម.ក
២. ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី
៣. ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី
៤. ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់
៥. ធនាគារ វិនិយោគនិងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី
៦. ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក
៧. ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក
៨. ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី
៩. ធនាគារ សាយហ្គន ធឿងទីន (ខេមបូឌា) ភីអិលស៊ី ហៅ ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី
១០. ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី
១១. សាជីវកម្មធនាគារកាថេយូណៃធីត(កម្ពុជា) ចំកាត់
១២. ធនាគារ សហពាណិជ្ជ ក.អ
១៣. ធនាគារ ហ្វីលីព ភីអិលស៊ី
១៤. ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី
១៥. ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី
១៦. ធនាគារ ហត្ថា ម.ក
១៧. ធនាគារ ឌីជីប៊ី ម.ក
១៨. ធនាគារ អ៊ូរី (ខេមបូឌា) ម.ក
១៩. ធនាគារ អ៊ឹមប៊ី (ខេមបូឌា) ម.ក
២០. ធនាគារ ខេប៊ីប្រាសាក់ ម.ក

## ៩ ធនាគារឯកទេស

១. ធនាគារឯកទេស អានកូ
២. ធនាគារឯកទេស ភី អេច អែស អ៊ឹម អ៊ី ចំកាត់
៣. ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
៤. ធនាគារឯកទេស អង្គរ កាពីតាល
៥. ធនាគារឯកទេស ដួនពេញ ម.ក
៦. ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
៧. ធនាគារឯកទេស សារធើន យៃភីថល ភីអិលស៊ី
៨. ធនាគារឯកទេស ម៉ារីថាម ម.ក
៩. ធនាគារឯកទេស អេវើហ្វ្រេស៍ (ខេមបូឌា) ម.ក

## ៥ ការិយាល័យតំណាង

១. ធនាគារ ស្តាន់ដាឆាទើរែត ភ្នំពេញ
២. ធនាគារពាណិជ្ជ វិនិយោគ និងអភិវឌ្ឍន៍ នៃ វៀតណាម
៣. ធនាគារស៊ូមីតូម៉ូ មីតស៊ុយប៊ែងឃីងខបភើរេសិន
៤. ធនាគារសៀងហៃ ខមមែសល & សេវរីង
៥. ធនាគារ អិចផត-អ៊ីមផត ប៊ែង អហ្វ ថៃលែន

## ៣.៣៣៤ អាជីវកម្មប្តូរប្រាក់

**សរុបនៅភ្នំពេញ៖ ៨៨**

- អាជ្ញាបណ្ណ៖
  - ធនាគារ៖ ៧
  - គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖ ២
  - នីតិបុគ្គល៖ ២៦
  - រូបវន្តបុគ្គល៖ ៣
- លិខិតអនុញ្ញាត៖ ៥០

**សរុបនៅសាខាខេត្ត៖ ៣.២៤៦**

- អាជ្ញាបណ្ណ៖
  - ធនាគារ៖ ៣
  - គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ៖ ១
  - នីតិបុគ្គល៖ ១
- លិខិតអនុញ្ញាត៖ ៣.២៤១

## ៨៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

### ៨៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ

១. សីលានិធិ លីមីធីត
២. វ៉េលខម ហ្វាយនែន (ខេមបូឌា) ម.ក
៣. ម៉ាក់ស៊ីម៉ា ភីអិលស៊ី
៤. ឥណទានពលរដ្ឋរុងរឿង អិលធីឌី
៥. ណុងហឹប ហ្វាយនែន (ខេមបូឌា) ម.ក
៦. ហ្វាមើរ ហ្វាយនែន អិលធីឌី (អេហ្វ.អេហ្វ)
៧. ហ្វីស ហ្វាយនែន ភីអិលស៊ី
៨. វ៉ាយ ស៊ី ភី ម៉ាយក្រូហ្វាយនែន ម.ក
៩. សំរឹទ្ធិស័ក មីក្រូហិរញ្ញវត្ថុ លីមីតធីត
១០. ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត
១១. ខេមរៈ លីមីធីត
១២. ប្រាយម៍ អិមអេហ្វ អិលធីឌី (ប្រាយម៍អិមអេហ្វ)
១៣. សូណាត្រា ភីអិលស៊ី
១៤. ចម្រើន ម.ក
១៥. អាក់ទីវភីភល ភីអិលស៊ី
១៦. បាយ័ន ក្រេឌីត ម.ក
១៧. បរិបូរណ៍ ភីអិលស៊ី
១៨. ឃ្វីន ហ្វាយនែន ម.ក
១៩. ស៊ីធី ភីអិលស៊ី
២០. អមតៈ ខាប់ភីថល ភីអិលស៊ី
២១. សច្ចៈ ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
២២. អ្យូរ៉ូ ហ្វាយនែនខប ភីអិលស៊ី
២៣. និរន្តរ ភីអិលស៊ី
២៤. ខែលតា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
២៥. សេនជូរី ខេមបូ ឌីវេឡុបមេន ភីអិលស៊ី
២៦. ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក
២៧. ពិភពថ្មី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
២៨. សិរីឧត្តម មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
២៩. សម្បត្តិ ហ្វាយនែន ភីអិលស៊ី
៣០. ប៊ីអេនខេស៊ី (ខេមបូឌា) ភីអិលស៊ី
៣១. ប៉ែមប៊ូ ហ្វាយនែន ភីអិលស៊ី
៣២. សហគ្រិនភាពម៉ាយក្រូហ្វាយនែនភីអិលស៊ី
៣៣. ឆាយលីស រ៉ូយ៉ាល់ ហ្វាយនែន ម.ក
៣៤. ធីប៊ីប៊ី (ខេមបូឌា) ភីអិលស៊ី
៣៥. រ៉ូយ៉ាល់ ម៉ាយក្រូហ្វាយនែន ភីអិលស៊ី
៣៦. សាន់នី ម៉ាយក្រូហ្វាយនែន ម.ក
៣៧. ហ្វូណាន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៣៨. សម្ព័ន្ធសមាគម សហគ្រាសធុនតូច និង មធ្យមកម្ពុជា ភីអិលស៊ី
៣៩. សាមគ្គី ឃែភីថល ម.ក
៤០. ខេមបូឌាន ឡេប៊ី យៃវ៍ ភីអិលស៊ី
៤១. ខេម ខាប់ភីថល ម.ក
៤២. គង្គា ឃែភីថល អិមអេហ្វអាយ ម.ក
៤៣. ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៤៤. អ៊ីខែមីតស៊ុ សែហ្សុង ម៉ាយក្រូហ្វាយនែន (ខេមបូឌា) ម.ក
៤៥. ម៉ាខែរ ហ្វាយនែនសល យេផេន ភីអិលស៊ី
៤៦. សហការ ភីអិលស៊ី
៤៧. ហ្គោលដិន យែស ភីអិលស៊ី
៤៨. ជោគជ័យ ហ្វាយនែន ភីអិលស៊ី
៤៩. សប្បាយ ក្រេឌីត ខមមើសល ភីអិលស៊ី
៥០. ជេត យែស បកស៍ ហ្វាយនែន ភីអិលស៊ី
៥១. លីដ ភីអិលស៊ី
៥២. អិល ប៊ី ភី មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៥៣. ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី
៥៤. ធី & ហ្គ ហ្វាយនែន ភីអិលស៊ី
៥៥. អនាគត ភីអិលស៊ី
៥៦. ប្រាក់ ម.ក
៥៧. បៃតង មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
៥៨. មីយ៉ា ម.ក
៥៩. ឡេង ណាវាត្រា ឃែភីថល ម.ក
៦០. វិថី ម៉ាយក្រូហ្វាយនែន ម.ក
៦១. ទ្រព្យខ្ញុំ ម.ក
៦២. ខ្មែរ ឃែភីថល ម.ក
៦៣. ភីជី ឌីវេឡុបម៉ិន ម.ក
៦៤. ជេស៊ី ហ្វាយនែន ម.ក
៦៥. ស៊ីអិមខេ ម.ក
៦៦. រ៉ូល្យា ម.ក
៦៧. អិលស៊ីអេច ម៉ាយក្រូហ្វាយនែន ម.ក
៦៨. ហ្វាមីលី ម.ក
៦៩. ប្រពៃ ម៉ាយក្រូហ្វាយនែន ម.ក
៧០. ស៊ិកធី ស៊ិកស៍ ហ្វាយនែន ម.ក
៧១. ជី ប៊ី ម.ក
៧២. អេវើហ្គ្រីន ម៉ាយក្រូហ្វាយនែន ម.ក
៧៣. វ៉ាយ.អិល.ភី មីក្រូហិរញ្ញវត្ថុ ម.ក
៧៤. សាវ៉ាត រុងរឿង ហ្វាយនែន (ខេមបូឌា) ម.ក
៧៥. មែងហ្គោ ហ្វាយនែន ម.ក
៧៦. ខូរីច ម៉ាយក្រូហ្វាយនែន ម.ក
៧៧. វិវឌ្ឍន៍ ហ្គោលឌិន ហ្វាយនែន ម.ក
៧៨. សាយ ហ្វូសថល ម៉ាយក្រូហ្វាយនែន ម.ក
៧៩. សុខសាន្ត ម.ក
៨០. អេអិមហ្សេត ម.ក
៨១. ជេកស៍ (ខេមបូឌា) ម.ក
៨២. អ៊ីស្គ មីក្រូ ម.ក
៨៣. វ៉ាហ្វូកូ ហ្វាយនែនសល (ខេមបូឌា) ម.ក
៨៤. អេច អេហ្វ ស៊ី (ខេមបូឌា) មីក្រូហ្វាយនែន ម.ក
៨៥. រីច អ៊ែរីន្ស៊ូ ហ្វាយនែន ម.ក

### ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

១. អម្រឹត ម.ក
២. អេ អឹម ខេ ភីអិលស៊ី
៣. អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
៤. មហានគរ ម.ក

## ១៣ គ្រឹះស្ថានឥតិសន្យាហិរញ្ញវត្ថុ

១. ប៊ីអេសភី ហ្វាយនែន (ខេមបូឌា) ម.ក
២. មេហ្គា លីស៊ីង ភីអិលស៊ី
៣. សួស្តី ហ្វាយនែន ភីអិលស៊ី
៤. ខេខេហ្វាន់ លីស៊ីង ភីអិលស៊ី
៥. តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន (ខេមបូឌា) ភីអិលស៊ី
៦. ម៉ូប៊ីលីធី ហ្វាយនែន (ខេមបូឌា) ម.ក
៧. ឆាយលីស រ៉ូយ៉ាល់ លីស៊ីង ម.ក
៨. ខូម៉ាត់ស៊ុ លីស៊ីង (ខេមបូឌា) ម.ក
៩. គូបូតា លីស៊ីង (ខេមបូឌា) ម.ក
១០. អិល អូ ឌី លីស៊ីង ម.ក
១១. អាយយែរ លីស៊ីង ម.ក
១២. ហ្វរវើដ លីស៊ីង ម.ក
១៣. វី ស៊ីវីស លីស៊ីង ម.ក

## ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី

## ២១ សាខាធនាគារជាតិនៅតាមខេត្ត

១. ភ្នំពេញ
២. កំពង់ចាម
៣. ព្រះសីហនុ
៤. សៀមរាប
៥. បាត់ដំបង
៦. បន្ទាយមានជ័យ
៧. ស្វាយរៀង
៨. កណ្តាល
៩. កំពត
១០. កំពង់ធំ
១១. ពោធិ៍សាត់
១២. កំពង់ស្ពឺ
១៣. កោះកុង
១៤. រតនគិរី
១៥. ព្រៃវែង
១៦. តាកែវ
១៧. កំពង់ឆ្នាំង
១៨. ព្រះវិហារ
១៩. ក្រចេះ
២០. ស្ទឹងត្រែង
២១. មណ្ឌលគិរី

## ១២ ក្រុមហ៊ុនសវនកម្ម

១. ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា
២. ក្រុមហ៊ុន ម៉ូរីសុនកាក់ អិមខេអេ អឌីត-អឹខោនធីង ឯ.ក
៣. ក្រុមហ៊ុន ប្រាយវ៉េតផ័រហោវខូភើស៍ (ខេមបូឌា)
៤. ក្រុមហ៊ុន អឺនស្ទ អ៊ែន យ៉ាំង (ខេមបូឌា)
៥. ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីធីត
៦. ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
៧. ក្រុមហ៊ុន ឌីឡូយថ៍ (ខេមបូឌា) ខូ អិលធីឌី
៨. ក្រុមហ៊ុន អេហ្វអាយអាយ & អឹសូស៊ីអេត
៩. ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក
១០. ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក
១១. ក្រុមហ៊ុន ខេម អឹខោនធីង & ថាក ស៊ីវីស ឯ.ក
១២. ក្រុមហ៊ុន រីចឆ៍ & ផាតនើរ

## ៤ អ្នកដំណើរការតតិយភាគី

១. ក្រុមហ៊ុន Western Union Network (Ireland) Limited
២. ក្រុមហ៊ុន MoneyGram Payments System, Inc.
៣. ក្រុមហ៊ុន Dandelion Payments, Inc.
៤. ក្រុមហ៊ុន ណូវើស ថេកណូឡូជី (ខេមបូឌា) ខមភេនី លីមីធីត

## ៣០ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

១. គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក
២. គ្រឹះស្ថាន លី ហ្វូរ ផេ ប្រ៉ូ ភីអិលស៊ី
៣. គ្រឹះស្ថាន ផាយ ផេ ម.ក
៤. គ្រឹះស្ថាន អេស៊ា យែស អិចប្រេស ម.ក
៥. គ្រឹះស្ថាន ស៊ីធេល ហ្វាយនែនសល សឺវីស ម.ក
៦. គ្រឹះស្ថាន អាប៊ីត្រេរី ផេយ ម.ក
៧. គ្រឹះស្ថាន អ៊ីឌាល (ខេមបូឌា) ម.ក
៨. គ្រឹះស្ថាន អាយផេ88 (ខេមបូឌា) ម.ក
៩. គ្រឹះស្ថាន បងឡូយ ផេម៉ិន ម.ក
១០. គ្រឹះស្ថាន ធានស៊ូ អ៊ិនធើណេសិនណល ថេកណូឡូជី ម.ក
១១. គ្រឹះស្ថាន ហួយវ៉ែ ផេម៉ិន ម.ក
១២. គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេម៉ិន សឺលូសិន ម.ក
១៣. គ្រឹះស្ថាន ជ្រេហ្គនហ្លាយ ហ្វីនថេក (ខេមបូឌា) ម.ក
១៤. គ្រឹះស្ថាន ដាយនែមីក ផេម៉ិន ម.ក
១៥. គ្រឹះស្ថាន តារាសាគរ ផេ ម.ក
១៦. គ្រឹះស្ថាន បៃ សេន ថេកណូឡូជី ម.ក
១៧. គ្រឹះស្ថាន អ៊ែរទ្រីណូ គ្លូបល ម.ក
១៨. គ្រឹះស្ថាន ផារ៉ាហ្គន ផេម៉ិន សឺវីស ម.ក
១៩. គ្រឹះស្ថាន យេស អ៊ិននើវេសិន ម.ក
២០. គ្រឹះស្ថាន វ៉ៃ ផេ ម.ក
២១. គ្រឹះស្ថាន លីន ផេ ផេម៉ិន សឺលូសិន ម.ក
២២. គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក
២៣. គ្រឹះស្ថាន ស្តារផេ ហ្វីនថេក ម.ក
២៤. គ្រឹះស្ថាន ឡានតុន អ៊ិនធើណេសិនណល (ខេមបូឌា) ផេម៉ិន សឺវីស ម.ក
២៥. គ្រឹះស្ថាន គ្លីក ផេម៉ិន (ខេមបូឌា) ម.ក
២៦. គ្រឹះស្ថាន សាន់ផេ (ខេមបូឌា) ម.ក
២៧. គ្រឹះស្ថាន កៃ ហ្វូ តុង ផេម៉ិន ម.ក
២៨. គ្រឹះស្ថាន ផេយ៉ុន ម.ក
២៩. គ្រឹះស្ថាន ជីន ហុង ជិន ថេកណូឡូជី ម.ក
៣០. គ្រឹះស្ថាន ផេនទ័រ (ខេមបូឌា) ម.ក

## ១១៣ គ្រឹះស្ថានឥណទានជនបទ

១. ជូ ជីវ័ន ហ្វាយនែន ម.ក
២. គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ
៣. បវរ ហ្វាយនែន ម.ក
៤. ពាយ័ព្យ ហ្វាយនែន ម.ក
៥. សេន ហ្វាយនែនស៍ ម.ក
៦. មិត្តភាព ហ្វាយនែន ម.ក
៧. អិល.អ៊ី.ឌី.អេ យៃភីថល ម.ក
៨. លីដ-ធី អាយ ភី អេស ហ្វាយនែន ម.ក
៩. ដៃគូ ហ្វាយនែន ភីអិលស៊ី
១០. ព្រះខ័ន អភិវឌ្ឍន៍ ម.ក
១១. ក្រេប៉ូ ហ្វាយនែន ម.ក
១២. វី.ភីដិច ម.ក
១៣. សិរីសួស្តី ពាណិជ្ជ ភីអិលស៊ី
១៤. អូស៊ីដាហ្វ ហ្វាយនែន ម.ក
១៥. ជ ម៉ីជីង ហ្វាយនែន ម.ក
១៦. ហ៊ីគាន ហ្វាយនែន ម.ក
១៧. កូនខ្មែរ មង្គលហិរញ្ញវត្ថុ ម.ក
១៨. មានជ័យ ក្រេឌីត ម.ក
១៩. ប្រសើរ ហ្វាយនែន ម.ក
២០. មាគ៌ា ហ្វាយនែន ម.ក
២១. ខេភីស៊ីអេ ហ្វាយនែន ម.ក
២២. ដាកូ ហ្វាយនែន ភីអិលស៊ី
២៣. សំណាង ប្រតិបត្តិការ ម.ក
២៥. គុណភាព ហ្វាយនែន ម.ក
២៦. សំរឹទ្ធិ ពេជ្រ ហ្វាយនែន ម.ក
២៧. ប៊ី.វ៉ាយ.ជី ហ្វាយនែន ម.ក
២៨. ឃ្វីក អមត: ម.ក
២៩. អិលអេច ហ្វាយនែន ម.ក
៣០. បៃតង ហ្វាយនែន ម.ក
៣១. ខេ.ឌី.អូ ហ្វាយនែន ភីអិលស៊ី
៣២. ជុំ សំណាង ហ្វាយនែន ម.ក
៣៣. ខេម ហ្វាយនែន ម.ក
៣៤. ឥណទាន អ៊ីហ្ស៊ី ហ្វាយនែន ភីអិលស៊ី
៣៥. មរតក អភិវឌ្ឍន៍ ភីអិលស៊ី
៣៦. កល្យាណ អភិវឌ្ឍន៍ ភីអិលស៊ី
៣៧. ភូមិន្ទ ក្រេឌីត ភីអិលស៊ី
៣៨. វីរៈបុត្រ ហ្វាយនែន ភីអិលស៊ី
៣៩. ពន្លឺកសិករខ្មែរ ភីអិលស៊ី
៤០. ឥណទាន ជនបទខ្មែរ (អ៊ីស៊ីខេ) ភីអិលស៊ី
៤១. អេស អេច ជី ហ្វាយនែន ភីអិលស៊ី
៤២. អរ អេន ឌី ប៊ី ហ្វាយនែន ភីអិលស៊ី
៤៣. ផ្កាឈូក ហ្វាយនែន ភីអិលស៊ី
៤៤. សុខសប្បាយ ហិរញ្ញវត្ថុ ម.ក
៤៥. ខេ.ខេ.ស៊ី.អិម ហ្វាយនែន ម.ក
៤៦. ប្រសិទ្ធិភាព ក្រេឌីត ភីអិលស៊ី
៤៧. ហ្លួបល ឡែនឌីង ហ្វាយនែន ភីអិលស៊ី
៤៨. អិល ឌី អេ ហ្វាយនែន ភីអិលស៊ី
៤៩. ឥណទាននារី ហ្វាយនែន ភីអិលស៊ី
៥០. ពិដោរ ប្រេក្តា ម.ក
៥១. ស្កាយ ឡាយ ហ្វាយនែន ម.ក
៥២. តារា ហ្វាយនែន ភីអិលស៊ី
៥៣. កូនកសិករ ហ្វាយនែន ភីអិលស៊ី
៥៥. អមត:រុងរឿង ម.ក
៥៦. ខ្មែរអង្គរ ហ្វាយនែន ភីអិលស៊ី
៥៧. គន្ធាម ហ្វាយនែន ម.ក
៥៨. សំបូរណ៍ ទ្រព្យ ហ្វាយនែន ភីអិលស៊ី
៥៩. ទីបុត្តា ហ្វាយនែន ម.ក
៦០. ស៊ី.ខេ ហ្វាយនែន ម.ក
៦១. វ៉ាយស្មាត ហ្វាយនែន ម.ក
៦២. សម្រឹត ក្រេឌីត ម.ក
៦៣. អង្គរ ឆព្វណ្ណ ហ្វាយនែន ម.ក
៦៤. កាក់កប ហ្វាយនែន ម.ក
៦៥. ស្មាយ ហ្វាយនែន ម.ក
៦៦. សកល ហ្វាយនែន ម.ក
៦៧. ឥណទាន លើកស្ទួយ សមត្ថភាព គ្រួសារ ម.ក
៦៨. ព្រះច័ន្ទ ហ្វាយនែន ម.ក
៦៩. អូណូ ហ្វាយនែន ម.ក
៧០. យូនីដា ហ្វាយនែន ម.ក
៧១. អេហ្វអេចអេហ្វ យៃភីថល ម.ក
៧២. ប្លូ ហ្វាយនែន ម.ក
៧៣. ខេមរា ហ្វាយនែន ម.ក
៧៤. ខេមហ្វាន់ ប្រាថ្នា ម.ក
៧៥. អេអេហ្វជី ហ្វាយនែន ម.ក
៧៦. ម៉ាមេឌី ហ្វាយនែន ម.ក
៧៧. វីរៈស័ក ហ្វាយនែន ម.ក
៧៨. វ៉ាឆា ម.ក
៧៩. ឥណទានមូលដ្ឋាន ម.ក
៨០. សម្របសម្រួល ហ្វាយនែន ម.ក
៨១. ពិស្ណុកា ហ្វាយនែន ម.ក
៨២. ប្រាក ហ្វាយនែន ម.ក
៨៣. លីជូ យៃភីថល ម.ក
៨៥. ខេ អ៊ី ភី ហ្វាយនែន ម.ក
៨៦. ពន្លឺស្នាមញញឹម ហ្វាយនែន ម.ក
៨៧. រស្មីសិរីមង្គល ហ្វាយនែន ម.ក
៨៨. មេត្តា ហ្វាយនែន ម.ក
៨៩. អេហ្វធី យៃស អិចប្រេស ម.ក
៩០. រស្មីជ័យជំនះ ម.ក
៩១. វីកវាយ ហ្វាយនែន ម.ក
៩២. ស៊ី.ខេ.អិល.អេស ហ្វាយនែន ម.ក
៩៣. យូនីត្រាស់ ហ្វាយនែន ម.ក
៩៤. ជីប៊ីអាយធី ហ្វាយនែន ម.ក
៩៥. ឥណទាន អភិវឌ្ឍន៍ អាជីវកម្ម ម.ក
៩៦. គ្រីស្គាល់ ហ្វាយនែន ម.ក
៩៧. អេស ប៊ី អី ហ្វាយនែន ម.ក
៩៨. ស៊ី.វី.អេ ហ្វាយនែន ម.ក
៩៩. អាខាបារ ម.ក
១០០. រិទ្ធី ហ្វាយនែន ម.ក
១០១. សមធម៌ ហ្វាយនែន ម.ក
១០២. ផាតនើរ អ៊ិន ខមភែសសិន ហ្វាន់ ម.ក
១០៣. រាហ្វ៊ី ហ្វាយនែន ម.ក
១០៤. សុវណ្ណភូមិ សូសល ឌីវេឡុបម៉ិន ម.ក
១០៥. ធិតិមា ហ្វាយនែន ម.ក
១០៦. អេស.អិម.អ៊ី.អេស អេកូ ហ្វាយនែន ម.ក
១០៧. ផានីតដា ហ្វាយនែន ម.ក
១០៨. អូខិនដិន មេត្រី ឥណទាន ម.ក
១០៩. វ៉ាយ ផ្លេស រាយស៍ អាប់ ហ្វាយនែន ម.ក
១១០. ហ៉ាប ហ្វាន់ ម.ក
១១១. មរកត ហ្វាយនែនសល ម.ក
១១២. វី សីវីស ហ្វាយនែន ម.ក
១១៣. ឧដុង្គ ហ្វាយនែន ម.ក

## ឧបសម្ព័ន្ធ ៣

## បញ្ជីឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| ល.រ | ឈ្មោះធនាគារ | អាសយដ្ឋាន | ទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|
| **១. ធនាគារពាណិជ្ជ** | | | |
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | #៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 998 777 |
| ២ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | អគារលេខ១៤១ ១៤៦ ១៤៨ & ១៤៨ អា បេ សេ ដេ & ១៦២ អា មហាវិថីព្រះសីហនុ ផ្ទះលេខ១៥ & ១៥៣ អា បេ សេ ផ្លូវលេខ២៧៨ ផ្ទះលេខ១៧១ ផ្លូវព្រះត្រសក់ផ្អែម ភូមិភូមិ៤ សង្កាត់បឹងកេងកងទី ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ | 023 225 333 |
| ៣ | ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម | អគារលេខ១៦៨ ផ្លូវបេតុងលេខ៧ ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | 023 220 810 / 023 220 811 |
| ៤ | ធនាគារពាណិជ្ជ អាល់ហ្វា ម.ក | អគារឌឹហ្គេតវេយ៍ ជាន់ផ្ទាល់ដី និងទី៣៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ | 023 886 688 |
| ៥ | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិក ឌីវេឡុបមេន ម.ក | អគារលេខ សេ២០ សេ២១ សេ២២ សេ២៣ ដេ៣២ ដេ៣៣ & ដេ៣៣អា នៃផាក ផ្លូវលេខអ៊ែរ៨ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 098 399 888 |
| ៦ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | អគារលេខ ៤៦២ ជាន់ផ្ទាល់ដី និងជាន់ទី១ មហាវិថីព្រះមុនីវង្ស ភូមិ ១៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | 023 901 338 |
| ៧ | ធនាគារ បាងកក មហាជនទទួលខុសត្រូវមានកម្រិត សាខាកម្ពុជា | #៣៨៤ (ជាន់ទី១ និងទី២) មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ | 023 224 404 |
| ៨ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី | #២៣៥ មហាវិថីព្រះនរោត្តម ភូមិភូមិ ១៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | 023 210 044 |
| ៩ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ | វិមានកាណាឌីយ៉ា (៣១៥) ជាន់ទី១-ទី២ មហាវិថីព្រះមុន្នីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 988 886 |
| ១០ | ធនាគារ ប៊ូយ៉ុង ខ្មែរ | អគារប៊ូយ៉ុងថោន១ ជាន់ផ្ទាល់ដី បន្ទប់លេខ១១៧ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិប៉ុរីកម្មករ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ | 023 952 888 |
| ១១ | សាខាធនាគារ អ៊ិនដាសស្រៀល ប៊ែង អហ្វ ខូរៀ "ភ្នំពេញ" | អាគារលេខ S២-២៣ ដីអូឡាំព្យា ស៊ីធី មហាវិថីព្រះមុនីរ៉េត (លេខ ២១៧) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ | 023 964 202 / 012 608 898 |
| ១២ | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) | ផ្ទះលេខ៤៥ មហាវិថីព្រះសីហនុ កែងផ្លូវលេខ ៥៩ ភូមិ៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 077 555 366 / 023 214 998 / 023 214 999 |
| ១៣ | សាខាធនាគារ មីហ្ស៊ូហូ អិលធីឌី | អគារលេខ១៣២ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | 023 964 490 |
| ១៤ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | #៣០ មហាវិថី ព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 092 233 850 / 023 999 222 |
| ១៥ | ធនាគារ ប្រ៊ីដ ម.ក | ផ្ទះលេខ៩២ មហាវិថីព្រះនរោត្តម ភូមិ៣ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 213 111 / 023 222 068 |
| ១៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ផ្ទះលេខ៧៥សេ.០៣៦ វិថីព្រះសីហនុ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ | 023 980 000 |
| ១៧ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | អគារលេខ២៦៣ ជាន់ទី១ - ៦ ផ្លូវលេខ១១០ កែង ៦១ ក្រុម១១ ភូមិ១ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 260 888 |
| ១៨ | ធនាគារ កម្ពុជាពាណិជ្ជ ម.ក | អគារលេខ២៦ មហាវិថីព្រះមុនីវង្ស សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 213 601 / 023 213 602 / 015 444 111 |
| ១៩ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | អគារលេខ២៣ ផ្លូវលេខ១១៤ សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 222 880 / 023 222 881 / 023 222 882 |
| ២០ | ធនាគារ កាណាឌីយ៉ា ក.អ | #៣១៥ វិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 868 222 |
| ២១ | សាជីវកម្មធនាគារកាថេយ្យយូណៃធីត(កម្ពុជា)ចំកាត់ | #៩៨ វិថីសម្តេចប៉ាន (២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 211 211 / 023 222 438 |
| ២២ | ធនាគារ ស៊ីស៊ីយូ ខមមើសល ប៊ែង ម.ក | ដីឡូត៍លេខ១៥ មហាវិថីព្រះមុនីវង្ស ភូមិ៥ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ | 099 333 878 |
| ២៣ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ផ្ទះលេខ សេ-០១ ផ្លូវអ៊ែ ១១ កែងផ្លូវ ៧០ ភូមិ ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 900 878 |
| ២៤ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | អគារលេខ១៧៤ ជាន់ទី១, ៣ & ៤ មហាវិថីសាធារណរដ្ឋឆែក កែងផ្លូវលេខ១៦៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ | 081 811 911 |
| ២៥ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | #២០ មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 988 388 |
| ២៦ | ធនាគារ ឌីជីប៊ី ម.ក | ផ្ទះលេខ៦៨៩បេ មហាវិថីកម្ពុជាក្រោម សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ | 023 999 990 |
| ២៧ | ធនាគារ ពាណិជ្ជទីមួយ សាខាភ្នំពេញ | #៦៦ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 012 712 111 |
| ២៨ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា | អគារលេខ៣៣សេ-ឌេ មហាវិថីសាធារណរដ្ឋឆែក សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ | 023 724 466 / 023 725 266 / 023 722 466 |
| ២៩ | ធនាគារ ហត្ថា ម.ក | ក្បាលដីលេខ ភព ៧២១៣៧ មហាវិថីសម្តេចហ៊ុនសែន ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | 023 999 266 |
| ៣០ | ធនាគារ ហេង ហ្វ៊ឹង (ខេមបូឌា) ម.ក | ដីឡូត៍លេខ៣៨២ មហាវិថីព្រះមុនីវង្ស កែងផ្លូវលេខ២៨៨ ភូមិ៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ | 088 8666 988 |
| ៣១ | ធនាគារ ហេងហ៊ី (ខេមបូឌា) ខមមើសល ប៊ែង ម.ក | អាគារលេខ៦៤ មហាវិថីព្រះនរោត្តម កែងផ្លូវលេខ១៧៨ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 997 777 |
| ៣២ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី | #២៨ ផ្លូវ ២១៤ កែង ផ្លូវ ៥១ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 999 711 |

## បញ្ជីឈ្មោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| ល.រ | ឈ្មោះធនាគារ | អាសយដ្ឋាន | ទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|
| ៣៣ | ធនាគារ អាយ ស៊ី ប៊ី ស៊ី លីមីធីត សាខាភ្នំពេញ | អាគារ Exchange Square (ជាន់ផ្ទាល់ដី) លេខ ១៩ និង ២០ ផ្លូវលេខ ១០៦ ភូមិ ២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 955 880 |
| ៣៤ | ធនាគារ អាយភីយូ ស៊ី ប៊ែង (ខេមបូឌា) ម.ក | ផ្ទះលេខ៣២៥ មហាវិថីម៉ៅសេទុង ភូមិ៧ សង្កាត់ផ្សារដេប៉ូទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ | 023 968 968 |
| ៣៥ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | អគារ Royal Railway លេខ១០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 999 000 |
| ៣៦ | ធនាគារ ខេប៊ីប្រាសាក់ ម.ក | អគារលេខ២១២ ផ្លូវលេខ២៧១ ភូមិ៤ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ | 023 999 911 / 086 999 911 |
| ៣៧ | ធនាគារ ក្រុងថៃ ចំកាត់ មហាជន សាខាភ្នំពេញ | #១៤៩ ផ្លូវលេខ២១៥ សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ | 023 882 959 |
| ៣៨ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | #៤៣, មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 210 255 / 023 210 123 |
| ៣៩ | ធនាគារ អ៊ឹមប៊ី (ខេមបូឌា) ម.ក | #១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | 023 964 666 |
| ៤០ | ធនាគារ មេហ្គា អិនធើណេសិនណល ខមមើសល ប៊ែង ខូ អិលធីឌី សាខាភ្នំពេញ | ផ្ទះលេខ១៣៩ ផ្លូវ២៧៤ កែងផ្លូវ ៥១ ភូមិ ភូមិ៥ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ | 023 988 101 / 023 218 540 |
| ៤១ | ធនាគារ អូរៀនថល ម.ក | អគារលេខ១០១ មហាវិថីព្រះនរោត្តម កែងនឹងវុក្ខវិថីសម្តេចប៉ាន(២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 920 222 / 023 920 111 |
| ៤២ | ធនាគារ ផេនដា ខមមើសល ប៊ែង ម.ក | ផ្ទះលេខ៣១ មហាវិថីម៉ៅសេទុង (២៤៥) សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ | 018 282 8375 |
| ៤៣ | ធនាគារ ភីក វេល ម.ក | អគារលេខ ៦៣៥&៦៣៧ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ | 081 292 237 / 023 989 736 |
| ៤៤ | ធនាគារ ហ្វីលីព ភីអិលស៊ី | អាគារលេខ ២៧ ដេអីអេហ្វហ្សេ មហាវិថីព្រះមុនីវង្ស ភូមិ៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 086 930 000 / 089 989 818 |
| ៤៥ | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក | #២១៧ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | 023 999 500 |
| ៤៦ | ធនាគារ ព្រីនស៍ ម.ក | អគារលេខ៤៤៥ ជាន់ទី១, ១៥ & ១៨ មហាវិថីព្រះមុនីវង្ស កែងផ្លូវ២៣២ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ | 1800 20 8888 / 023 991 168 |
| ៤៧ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក | អគារជាន់ទី១ ជាន់អឺម ជាន់ទី២ និងជាន់ទី៩ ផ្លូវលេខ១១០ កែងផ្លូវ៩៣ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 992 833 |
| ៤៨ | ធនាគារ សាយហ្គន ធឿងទីន (ខេមបូឌា) ភីអិលស៊ី ហៅ ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី | #៦០ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 223 422 |
| ៤៩ | ធនាគារ សៃហ្គន-ហាណូយ កម្ពុជា ភីអិលស៊ី | #១០៧ មហាវិថីនរោត្តម សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 221 900 |
| ៥០ | ធនាគារ ស្ថាបនា ភីអិលស៊ី | អគារស្ថាបនា មហាវិថីព្រះនរោត្តម កែង ផ្លូវលេខ១៧២ និង ១៧៤ ភូមិ១៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 999 010 / 081 999 010 |
| ៥១ | ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក | អគារលេខ២១៩ ផ្លូវ១២៨កែងផ្លូវ១៦៩ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ | 023 980 888 / 023 999 368 |
| ៥២ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក | វ៉ាន់ដាថោវើ លេខ ៧៩ មហាវិថីកម្ពុជាក្រោម ភូមិ២ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ | 023 727 380 |
| ៥៣ | ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក "ធ.ស.ក" | អគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដីឡូត៍លេខ អេស ផ្លូវ អូស៊ីអាយស៊ី ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ | 096 811 1118 |
| ៥៤ | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ | #១៧១ មហាវិថីព្រះនរោត្តម កែងផ្លូវលេខ៣២២ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ | 023 430 800 |
| ៥៥ | ធនាគារ សហពាណិជ្ជ ក.អ | អាគារលេខ៤៤១ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ | 023 212 357 / 023 427 995 |
| ៥៦ | ធនាគារ វឌ្ឍនៈ | #៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | 023 963 999 |
| ៥៧ | ធនាគារ កសិកម្មនិងអភិវឌ្ឍន៍ជនបទ វៀតណាម សាខាកម្ពុជា (អាហ្គ្រីប៊ែង) | #៣៦៤ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ | 023 223 750 |
